សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

កិច្ចការស្រាវជ្រាវ

# ប្រព័ន្ធវិមជ្ឈការដែនដី

កិច្ចការស្រាវជ្រាវពីថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៣ ដល់ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៣

សាស្ត្រាចារ្យបង្រៀន

អ្នកគ្រូ **ហាង រស្មីផល្លា**

មុខវិជ្ជា **នីតិរដ្ឋបាលទូទៅ**

រៀបរៀងដោយ

**ក្រុមនិស្សិតថ្នាក់ *L2B5***

បរិញ្ញាបត្រ **នីតិសាស្ត្រ**

ថ្នាក់ *L2B5*

ក្រុមទី **២**

ប្រធានបទទី **២**

ឆ្នាំចូលសិក្សា **២០១២**

និស្សិតឆ្នាំទី **II**

២០១៣-២០១៤

**បណ្ណាល័យច្បាប់-Law Library**

**Lawlibrarysite.wordpress.com**

# អារម្ភកថា

សៀវភៅដែលលោកអ្នកកំពុងតែកាន់អាននេះ គឺជាវណ្ណកម្មរបស់ក្រុមយើងខ្ញុំនៃថ្នាក់L2B5 ផ្នែកនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលក្រុមរបស់យើងខ្ញុំបានខិតខំព្យាយាមស្រាវជ្រាវសរសេរឡើង ដើម្បីទុកជាចំណងដៃសម្រាប់អស់លោកអ្នកដែលស្នេហានិស្ស័យវិស័យចំណេះដឹងនៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។ ហេតុដែលក្រុម របស់យើងខ្ញុំព្យាយាម សរសេរនេះ គឺក្រុមយើងខ្ញុំយល់ឃើញថាសៀវភៅ ក្បួនច្បាប់ផ្សេងៗ ផ្នែកសីលធម៌នៅក្នុងសង្គម របស់ប្រទេសកម្ពុជាយើងដែលបានបាត់បង់ជាច្រើន នៅពេលប្រទេសយើងជួបវិបត្តិ។ ពេលនោះគឺជា កំឡុងពេល ដ៏អាក្រក់ដែលសៀវភៅ ក្បួនច្បាប់ផ្សេងៗដែលជាស្នាដៃរបស់អ្នកនិពន្ធ រៀមច្បងយើងខំបង្កើតឡើង ទុកឲ្យយើងជាជាជាតិខ្មែរ ជំនាន់ក្រោយសម្រាប់រៀនសូត្រត្រូវបានបំផ្លាញ។ ឥឡូវនេះក្រុមយើងខ្ញុំមានកាលានុវត្តភាព ជួបជាមួយអស់លោកអ្នក តាមរយៈសំនេររបស់ក្រុមយើងខ្ញុំ ទុកជាចំណងដៃ សម្រាប់លោកអ្នកអានក្នុងសហស្សវត្សន៍ថ្មីនេះ។ ហើយម្យ៉ាងទៀតកម្រងឯកសារដែលបានលើកឡើងក្នុងអត្ថបទដែលមិត្តអ្នកអាន និស្សិត លោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ កំពុងតែអាននេះ មានចំណងជើង ជាខេមរភាសាថា "**ប្រព័ន្ធខមជ្ឈការដែនដី**" ។

ខ្ញុំសង្ឃឹម និង ជឿជាក់ថានៅក្នុងការស្រាវជ្រាវរបស់ក្រុមយើងខ្ញុំនេះទោះបីជាមានការខិតខំព្យាយាមពិនិត្យផ្ទៀងផ្ទាត់យ៉ាងណាក៏ដោយក៏នៅតែមានភ្លាំងភ្លាត់ខុសឆ្គងខ្លះៗ ដោយអចេតនាពុំខាន។បើដូច្នេះខ្ញុំសូមអរភ័យទោស អំពីសំណាក់ អស់លោក មិត្តអ្នកអានទុកជាមុននូវរាលកំហុសឆ្គងទាំងឡាយដែលអាចកើតមានដោយចេតនាក្តី អចេតនាក្តី សូមខន្តីអរភ័យទោសដោយការគោរពយ៉ាងស្មោះស្មគ្រ័ពីសំណាក់ក្រុមរបស់យើងខ្ញុំ ហើយក៏ទទួលស្វាគមន៍នូវរាល់ការរិះគន់បែបស្ថាបនាដើម្បីកែលំអព្រមទាំងបន្ថែមនូវគំនិតល្អៗដើម្បីបន្សល់ទុកឲ្យកូនខ្មែរជំនាន់ក្រោយក្នុងការសិក្សា។

ជាទីបញ្ចប់នេះ យើងខ្ញុំសូមប្រសិទ្ធពរដល់មិត្តអ្នកអានទាំងអស់ ដែលជាក្រុមនិស្សិត លោកគ្រូអ្នកគ្រូ ក៏ដូចជាប្រជាពលរដ្ឋខ្មែរគ្រប់រូបឲ្យជួបប្រទះតែសំណាង សុខភាពល្អ និងទទួលបាននូវជោគជ័យនៅក្នុងជីវិតគ្រប់ភារកិច្ច។

*រាជធានីភ្នំពេញ,ថ្ងៃទី ខែ ឆ្នាំ២០១៣*

*និស្សិតជំនាញនីតិសាស្ត្រថ្នាក់L2B5*

# សេចក្តីថ្លែងអំណរគុណ

ក្នុងនាមក្រុមរបស់យើងខ្ញុំជាសិស្សនិស្សិតឆ្នាំសិក្សា២០១៣-២០១៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ជាការសិក្សាស្រាវជ្រាវទៅលើការប្រពន្ធ័តុលាការនៅកម្ពុជា បានបញ្ចប់នូវដំណើរការនៃការស្រាវជ្រាវ និង ចេញរបាយការណ៍របស់ខ្លួនដោយជោគជ័យជាស្ថាពរពេលនេះ។ ក្នុងន័យនេះ យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ :

- ❖ មាតាបិតាយើងខ្ញុំ ដែលបានផ្តល់កំណើត ជួយផ្គត់ផ្គង់ ជ្រោមជ្រែង ឧបត្ថម្ភទាំងសម្ភារៈ និង ថវិកា គ្រប់បែបយ៉ាង ព្រមទាំងជំរុញលើកទឹកចិត្ត ឲ្យយើងខ្ញុំបានសិក្សាក្រេបយកចំនេះដឹង និងក្លាយជាពលរដ្ឋល្អក្នុងសង្គមថ្ងៃនេះ។
- ❖ មិត្តរួមក្រុមរបស់យើងខ្ញុំដែលបានចំណាយពេលវេលា ដ៏មានតម្លៃធ្វើការស្រាវជ្រាវយ៉ាងម៉ត់ចត់ទៅលើប្រធានបទនេះ ហើយ ចេះសហការគ្នាធ្វើការស្រាវជ្រាវយ៉ាងជិតស្និតដោយមិនគិតពីការនឿយហត់ ដោយបញ្ចេញមតិយោបល់យ៉ាងច្រើនទើបសម្រេចបានជាកម្រងឯកសារមួយនេះ។
- ❖ ឯកឧត្តម សាកលវិទ្យាធិការ សាកលវិទ្យាធិការរង គណៈកម្មការ និង សាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំដឹកនាំ និង គ្រប់គ្រងក្នុងគោលបំណងបណ្តុះបណ្តាលធនធានមនុស្ស ដើម្បីជាសសរទ្រូងប្រទេស។
- ❖ សាស្ត្រាចារ្យ **ហេង្ស រស្មីផល្លា** ដែលជាសាស្ត្រចារ្យបង្រៀនមុខវិជ្ជា **នីតិរដ្ឋបាលទូទៅ** ដែលបានយកចិត្តទុកដាក់ក្នុងការបង្ហាត់បង្រៀន ជួយលើកទឹកចិត្ត ត្រួសត្រាយផ្លូវ និងផ្តល់នូវដំបូន្មានល្អៗដល់កិច្ចការស្រាវជ្រាវនេះ។
- ❖ លើសពីនេះ សូមអរគុណដោយស្មោះស្ម័គ្រ និង មោទនភាពជាតិបំផុតចំពោះរាជរដ្ឋាភិបាលកម្ពុជាដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាប្រមុខដឹកនាំ ដែលបាននឹងកំពុងដឹកនាំនាវាកម្ពុជាលើផ្លូវនយោបាយដ៏ត្រឹមត្រូវមួយប្រកបដោយសុចរិតភាព រក្សាបាននូវសុខសន្តិភាព ស្ថេរភាព និង ការអភិវឌ្ឍន៍ ហើយដែលជាការផ្តល់ឱកាសយ៉ាងប្រសើរសំរាប់ការសិក្សា និង ការស្រាវជ្រាវរបស់ក្រុមយើងខ្ញុំនាពេលនេះ។

ជាទីបញ្ចប់ សូមប្រសិទ្ធិពរជ័យ សិរីសួរស្តី វិបុលសុខ បវរមហាប្រសើរដល់លោកអ្នកមានគុណទាំងអស់ទទួលបានជោគជ័យគ្រប់ភារកិច្ច និង សុខភាពរឹងមាំទទួលទានគ្រប់ៗគ្នា ព្រមទាំងពុទ្ធពរទាំងប្រាំប្រការទៀតគឺ អាយុ វណ្ណៈ សុខៈ ពលៈ និង បដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា

**ទំព័រ**

**អារម្ភកថា**..........i
**សេចក្តីថ្លែងអំណរគុណ**..........ii
**មាតិកា**..........iii
**I- សេចក្តីផ្តើម**..........១
១- លំនាំបញ្ហានៃការស្រាវជ្រាវ..........១
២- ចំណោទបញ្ហានៃការស្រាវជ្រាវ..........២
៣- គោលបំណងនៃការស្រាវជ្រាវ..........២
៤- សារៈសំខាន់នៃការស្រាវជ្រាវ..........៣
**II- និយមន័យ**..........៣
**III- មែកធាងវិមជ្ឈការ**..........៥
១- វិមជ្ឈការនយោបាយ..........៦
២- វិមជ្ឈការរដ្ឋបាល..........៧
២.១- វិសហមជ្ឈការ..........៨
២.២- ការប្រគល់អំណាច ឬ ប្រតិភូកម្ម..........៨
៣- វិមជ្ឈការសារពើពន្ធ..........៩
៤- វិមជ្ឈការសេដ្ឋកិច្ច ឬ ទីផ្សារ..........១០
**IV- ទំហំនៃវិមជ្ឈការ និង វិសហមជ្ឈការដែលរៀបចំនៅកម្ពុជា**..........១០
១- ទំហំវិមជ្ឈការ..........១០
២- ទំហំវិសហមជ្ឈការ..........១១
**V- លក្ខខណ្ឌវិមជ្ឈការប្រកបដោយជោគជ័យ**..........១២
១- ក្របខណ្ឌច្បាប់ដែលត្រូវបង្កើតឡើងច្បាស់លាស់..........១៣
២- ស្ថាប័នប្រកបដោយសមត្ថភាព..........១៣
៣- ប្រព័ន្ធគណនេយ្យភាព(ទំនួលខុសត្រូវ)..........១៤
៤- សង្គមស៊ីវិលសកម្ម..........១៥
**VI- ប្រវត្តិនិងការអនុវត្តន៍ប្រព័ន្ធវិមជ្ឈការនៅកម្ពុជា**..........១៦
**VII- បញ្ហាប្រឈមមុខចំពោះវិមជ្ឈការនៅកម្ពុជា**..........២១
១- ប្រព័ន្ធនៃការទទួលខុសត្រូវ និង តម្លាភាព..........២១
២- ការចូលរួម និង សង្គមស៊ីវិល..........២២

៣- ការរៀបចំចាត់ចែងសារពើពន្ធ....................................................................................២២
៤- ប្រភពចំណូលរបស់ឃុំ-សង្កាត់.................................................................................២៣
៤.១- ចំណូលមូលនិធិឃុំ-សង្កាត់...........................................................................២៣
៤.២- ចំណូលផ្ទាល់របស់ឃុំ-សង្កាត់.......................................................................២៤
៤.៣- ចំណូលមុខងារជាភ្នាក់ងារ............................................................................២៤
**VIII- សេចក្តីសន្និដ្ឋាន និង អនុសាសន៍**..........................................................................២៤
១- សេចក្តីសន្និដ្ឋាន..................................................................................................២៤
២- អនុសាសន៍.........................................................................................................២៦
**ឧបសម្ព័ន្ធ**
**ឯកសារយោង**

# វិមជ្ឈការដែនដី

## I- សេចក្តីផ្តើម

### ១- លំនាំបញ្ហានៃការស្រាវជ្រាវ

វិមជ្ឈការ ត្រូវបានប្រជាជាតិជាច្រើនលើពិភពលោកចាត់ទុកថា ជាមធ្យោបាយសម្រាប់កាត់បន្ថយភាពក្រីក្រ និងជាយន្តការមួយក្នុងការផ្តល់នូវកំណែទម្រង់ថ្នាក់រដ្ឋបាលមូលដ្ឋាន(ថ្នាក់ក្រោមជាតិ) និង ជាការផ្តល់នូវក្របខណ្ឌគ្រប់គ្រងការងារអោយមានប្រសិទ្ធភាព និង មានភាពល្អប្រសើរឡើងតាមរយៈការអនុវត្តប្រព័ន្ធគ្រប់គ្រងតាមបែបនយោបាយវិមជ្ឈការ។ ការរីកចម្រើនទៅមុខនៃសាកលភាវូបនីយកម្មនៃបណ្តាប្រទេសលើពិភពលោក ក្នុងការអនុវត្តការដឹកនាំតាម បែបវិមជ្ឈការបានធ្វើអោយមានការផ្លាស់ប្តូរនូវដំណើរការ ការងារ ទម្រង់គ្រប់គ្រង ហើយជា លទ្ធផលវិមជ្ឈការបានធ្វើអោយមានភាពជោគជ័យ និងបរាជ័យដោយសារតែបរិបទ និងយន្តការនៃការអនុវត្តមានលក្ខណ:តាមបទដ្ឋានផ្សេងៗគ្នានៃតំបន់ និងប្រទេសនីមួយៗ ដែលនេះវាស្រប ទៅនឹងស្ថានភាពទូទៅដែលគ្មានភាពច្បាស់លាស់មួយនៃអត្ថន័យ និងរបៀបនៃការអនុវត្តប្រព័ន្ធវិមជ្ឈការដែលមានភាពស្មុគស្មាញ និងមិនទាន់មានឯកភាពគ្នាលើគោលការណ៍រួមណាមួយរបស់វិមជ្ឈការនៅឡើយ។

យោងទៅតាមបរិបទនៃស្ថានភាពជាក់ស្តែងរបស់សង្គម ព្រះរាជាណាចក្រកម្ពុជាជាប្រទេសមួយដែលបានកំពុងអនុវត្តនូវនយោបាយវិមជ្ឈការរបស់ខ្លួន និង មានការកំណែទម្រង់ជាបណ្តើរៗដើម្បីឈានឆ្ពោះទៅរកការអភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធភាព និង ភាពស័ក្តិសិទ្ធិ ដោយការចូលរួមពីគ្រប់មជ្ឈដ្ឋានដែលពាក់ព័ន្ធ។ ប្រជាពលរដ្ឋកម្ពុជាគ្រប់រូបមានសិទ្ធិឈរឈ្មោះនិង បោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន ហើយប្រជាពលរដ្ឋក៏មានសិទ្ធិផង ដែរក្នុងការចូលរួម ដើម្បីធ្វើការសម្រេចចិត្តនានា និងបង្ហាញពីសេចក្តីត្រូវការរបស់ខ្លួនដែលនេះជាការឆ្លើយតបដែលមានតម្លាភាព និង ការទទួលខុសត្រូវរបស់អ្នកដឹកនាំនៅក្នុងថ្នាក់មូលដ្ឋាន ប្រយោជន៍ដើម្បីកែលម្អប្រសិទ្ធភាព និង ភាពជោគជ័យនៃការងាររបស់រដ្ឋាភិបាលផងដែរ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានផ្តល់នូវការទទួលខុសត្រូវ និងភារកិច្ចសំខាន់ៗជាច្រើនដែលខុសប្លែកទាំងស្រុងពីការទទួលខុសត្រូវ និង ការបំពេញភារកិច្ចមុនការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ២០០២។ ភារកិច្ចសំខាន់បំផុតរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ គឺការអភិវឌ្ឍន៍ឃុំ

សង្កាត់ និង លើកកម្ពស់សុខមាលភាពប្រជាពលរដ្ឋ ដោយមានការទទួលខុសត្រូវ និង មានគណនេយ្យភាពចំពោះប្រជាពលរដ្ឋរបស់ ខ្លួន។ ក្នុងប្រព័ន្ធវិមជ្ឈការក្រុមប្រឹក្សាឃុំ សង្កាត់គឺជាអ្នកធានាថា ប្រជាពលរដ្ឋមូលដ្ឋានចូលរួមយ៉ាងពេញលេញ ក្នុងដំណើរការធ្វើសេចក្តីសម្រេចទៅលើផែនការអភិវឌ្ឍន៍របស់ក្រុមប្រឹក្សាឃុំ សង្កាត់។ ចំណុចសំខាន់ទាំងនេះ ជាយន្តការមួយក្នុងការលើកស្ទួយជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅថ្នាក់មូលដ្ឋាន ឬសហគមន៍មូលដ្ឋានទាំងអស់អោយកាន់តែប្រសើរឡើយនូវវឌ្ឍនភាព និង ភាពរីកចម្រើន។

## ២- ចំណោទបញ្ហានៃការស្រាវជ្រាវ

ក្រុមប្រឹក្សាឃុំ សង្កាត់ ដែលត្រូវបានបោះឆ្នោតជ្រើសរើសឡើងដោយប្រជាពលរដ្ឋតាមលក្ខណៈប្រជាធិបតេយ្យនឹងធ្វើការអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួន តាមរយៈនយោបាយវិមជ្ឈការ ដើម្បីធ្វើការអភិវឌ្ឍន៍នៅថ្នាក់មូលដ្ឋាន។ នយោបាយវិមជ្ឈការ ជាការផ្តល់ឱកាសដល់ប្រជាពលរដ្ឋអោយចូលរួមកាន់តែទូលាយក្នុងការធ្វើសេចក្តីសម្រេចចិត្តនានា ដែលមានផលប៉ះពាល់ទៅលើ ជីវភាពរស់នៅរបស់ខ្លួនដូចជា លទ្ធិប្រជាធិបតេយ្យ អភិបាលកិច្ច គុណភាពជីវិត និងការធានាបានការអភិវឌ្ឍន៍ប្រកបដោយចិរភាព រួមទាំងការផ្តល់សេវាកម្មជាមូលដ្ឋានផងដែរ។

ដើម្បីធ្វើការសិក្សាស្រាវជ្រាវប្រធានបទ "នយោបាយវិមជ្ឈការដែនដី" អោយកាន់តែស៊ីជម្រៅ និង មានភាពច្បាស់លាស់ចំណោទបញ្ហាត្រូវបានលើកឡើងថា តើការអនុវត្តនយោបាយវិមជ្ឈការសម្រាប់ការអភិវឌ្ឍន៍នៅក្នុងប្រទេសកម្ពុជាបានឆ្លើយតប ទៅនឹងសេចក្តីតម្រូវការរបស់ប្រជាពលរដ្ឋកាន់តែប្រសើរឡើង តាមរយៈផ្នែកសេដ្ឋកិច្ច ផ្នែកសង្គមកិច្ច ផ្នែករដ្ឋបាល និង សន្តិសុខ ផ្នែកធនធានធម្មជាតិ និងបរិស្ថាន និង ផ្នែកយេនឌ័រយ៉ាងដូចម្តេច? សមត្ថភាពក្នុងការអនុវត្តនយោបាយវិមជ្ឈការទូទាំងប្រទេសមានដល់កម្រិតណា?

## ៣- គោលបំណងនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះ គឺមានគោលបំណងក្នុងការរួមចំណែក ធ្វើអោយប្រសើរឡើងនូវការអនុវត្តតាមបែបនយោបាយវិមជ្ឈការ និង ការធ្វើអោយកាន់តែប្រសើរឡើងនូវប្រសិទ្ធភាពនៃការផ្តល់សេវាកម្មដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន។ គោលបំណងចម្បងនៃការស្រាវជ្រាវនេះ គឺផ្តោតទៅលើគោលបំណងសំខាន់ៗគឺ៖

- ប្រវត្តិនៃការកកើតវិមជ្ឈការដែនដីនៅក្នុងប្រទេសកម្ពុជា។
- សិក្សាពីដំណើរការអនុវត្តវិមជ្ឈការនៅថ្នាក់មូលដ្ឋានរបស់ប្រទេសកម្ពុជា។
- សិក្សាពីកត្តារាំងស្ទះក្នុងការអនុវត្តនយោបាយវិមជ្ឈការកាលពីដំបូង។

- សិក្សាពីដំណើរការផ្តល់សេវានៅថ្នាក់មូលដ្ឋានរបស់ប្រទេសកម្ពុជា។
- សិក្សាពីដំណើរការទទួលសេវាមូលដ្ឋាន និង ប្រសិទ្ធភាពវិមជ្ឈការ។

ការស្រាវជ្រាវនេះផងដែរ គឺធ្វើការវិភាគទៅលើចំណុចទាំងឡាយ ដើម្បីស្វែងរកចំណុចខ្វះខាតដែលត្រូវកែលម្អ ព្រមទាំងធ្វើសេចក្តីសន្និដ្ឋានទៅលើគ្រប់ចំណុច និង ផ្តល់ជាអនុសាសន៍ទៅលើចំណុចកែលម្អ។

## ៤- សារសំខាន់នៃការសិក្សាស្រាវជ្រាវ

នយោបាយវិមជ្ឈការជាប្រព័ន្ធនៃការគ្រប់គ្រងមួយក្នុងការផ្តល់នូវសិទ្ធិ អំណាច និង ការផ្តល់ធនធានមួយចំនួនអោយដល់ក្រុមប្រឹក្សាឃុំ ក្នុងការអនុវត្តសកម្មភាពបម្រើផលប្រយោជន៍ប្រជាពលរដ្ឋកាន់តែប្រសើរ និង ក្នុងកំណែទម្រង់ជាបណ្តើរតាមស្ថានភាពមួយនៃបរិបទសង្គម និង ការកំណត់ដោយគោលនយោបាយរបស់រាជរដ្ឋាភិបាល។ ការផ្តល់សិទ្ធិ អំណាច និង ធនធានជាគោលការណ៍ចម្បង គឺដើម្បីធ្វើអោយក្រុមប្រឹក្សាឃុំក្លាយជានីតិបុគ្គល តាមរយៈនយោបាយវិមជ្ឈការរបស់រាជរដ្ឋាភិបាល ក៏ដូចជាក្រសួងមហាផ្ទៃ និង អន្តរក្រសួងផងដែរ។

## II- និយមន័យ

**វិមជ្ឈការ**(Decentralization) មានន័យថា សិទ្ធិ អំណាច ការទទួលខុសត្រូវ និងធនធានមួយចំនួនត្រូវបានផ្ទេរពីរដ្ឋាភិបាលថ្នាក់ជាតិ(ថ្នាក់កណ្តាល) ទៅក្រុមប្រឹក្សាឃុំ សង្កាត់ ដែលបោះឆ្នោតជ្រើសរើសដោយប្រជាពលរដ្ឋ តាមលក្ខណៈប្រជាធិបតេយ្យ[1]។

បើសិនជារដ្ឋមិនប្រមូលផ្តុំអំណាចរដ្ឋបាលតែម្នាក់ឯង ហើយទទួលស្គាល់អោយសមូហភាពផ្សេងទៀតមានអំណាចរដ្ឋបានសម្រេច ដោយស្វ័យភាព នូវរាល់កិច្ចការផងទាំងពួងដែលជាផលប្រយោជន៍ទូទៅរបស់ប្រជាជននៅក្នុងសមូហភាពនោះផ្ទាល់ ការគ្រប់គ្រងរបៀបនេះគេហៅថា ការគ្រប់គ្រងបែប**វិមជ្ឈការដែនដី** [2]។

**វិមជ្ឈការ** គឺជារបៀបមួយនៃការគ្រប់គ្រងរដ្ឋទោលដែលតាមរបៀបនេះរដ្ឋផ្ទេរអំណាចមួយចំនួនទៅឲ្យសមូហភាពដែនដី និង គ្រឹះស្ថានសាធារណៈ មួយកំណត់ជាក់លាក់អមទៅជាមួយនូវមធ្យោបាយរដ្ឋបាលហិរញ្ញវត្ថុ និង ការទទួលខុសត្រូវ។ អាចនិយាយម្យ៉ាងទៀតថា ជាការទទួល

[1] គ.ជ.វ.វ, ខែឧសភាឆ្នាំ២០០៨។
[2] សៀវភៅនីតិរដ្ឋបាលទូទៅ បោះពុម្ពលើកទី៤ ទំព័រ៣៩៣ របស់បណ្ឌិត សាយ បូរី។

ស្គាល់ស្វ័យភាពនៃការគ្រប់គ្រងពោលគឺ សេរីភាពនៃការសម្រេចកិច្ចការមូលដ្ឋានផ្ទាល់។ ស្វ័យភាពមិនមែនជាឯករាជភាពទេ ដូច្នោះរដ្ឋ ដើម្បីធានាឲ្យមានឯកភាពជាតិរដ្ឋត្រូវត្រួតពិនិត្យលើការគ្រប់គ្រងរបស់សមូហភាពវិមជ្ឈការ[3]។

វិមជ្ឈការ(Decentralization)មានន័យថា សិទ្ធិពិតប្រាកដ ការទទួលខុសត្រូវ ហើយធនធានពិតប្រាកដមួយចំនួន ត្រូវបានផ្ទេរពីថ្នាក់កណ្តាលរបស់រដ្ឋាភិបាលទៅក្រុមប្រឹក្សាឃុំ សង្កាត់តាមរយៈការបោះឆ្នោតជ្រើសតាំងតាមលក្ខណៈប្រជាធិបតេយ្យ ដែលត្រូវបានផ្តល់ស្វ័យភាពក្នុងការសម្រេចលើកិច្ចការនានា ដែលបានចែងនៅក្នុងច្បាប់[4]។ អត្ថន័យខាងលើនេះក៏ត្រូវបានបង្ហាញភាពស្របគ្នាផងដែរ ពីទីភ្នាក់ងារផ្តល់ជំនួយសហរដ្ឋអាមេរិចដែលហៅកាត់ថា USAIDដែលបានអោយនិយមន័យពាក្យវិមជ្ឈការថា ជាដំណើរការផ្ទេរអំណាចទៅអោយរដ្ឋបាលថ្នាក់មូលដ្ឋានដែលត្រូវបានធ្វើការជ្រើសតាំងដោយប្រជាពលរដ្ឋ[5]។

ការកំណត់និយមន័យវិមជ្ឈការ ជាកិច្ចការដែលពោរពេញដោយភាពពិបាក និង ស្មុគស្មាញ។ តាមការសិក្សាស្រាវជ្រាវបានបង្ហាញថា មាននិយមន័យ និងការផ្តល់ន័យជាច្រើនស្តីពីវិមជ្ឈការទោះណាជាមានទស្សនៈ និងទ្រឹស្តីបានលើកឡើងដោយយល់ថា វិមជ្ឈការសំដៅលើស្មារតីនៃការផ្ទេរសិទ្ធិអំណាចទំនួលខុសត្រូវធនធាន និងភារកិច្ចខាងមុខងារសាធារណៈទៅអោយរដ្ឋបាលថ្នាក់ទាបក៏ដោយ។ វិមជ្ឈការត្រូវបានបំបែកខ្លួនជាសមាសភាគសំខាន់ៗរួមមានវិមជ្ឈការនយោបាយ និងប្រជាធិបតេយ្យវិមជ្ឈការរដ្ឋបាល វិមជ្ឈការហិរញ្ញវត្ថុ និងសារពើពន្ធវិមជ្ឈការបច្ចេកទេស និងវិមជ្ឈកាសេដ្ឋកិច្ចជាដើម។

តាមទស្សនៈរបស់លោក Samaratunge បានចង្អុលបង្ហាញថាដោយសារតែវាជាគំនិតមួយដ៏ស្មុគស្មាញដូច្នេះហើយ ទើបវិមជ្ឈការត្រូវបានអោយនិយមន័យផ្សេងៗគ្នាតាមស្ថានភាពរស់នៅរបស់មនុស្ស ទៅតាមតំបន់ និងតាមប្រទេសផ្សេងៗគ្នា[6]។

វិមជ្ឈការ ជាដំណើរការនៃការផ្ទេរអំណាចទៅអោយរដ្ឋបាលមូលដ្ឋាន ដែលត្រូវបោះឆ្នោតជ្រើសតាំងដោយប្រជាពលរដ្ឋ។ គួរបញ្ជាក់ផងដែរថា សម្រាប់USAID វិមជ្ឈការទាមទារនូវអត្ថិភាពនៃរដ្ឋបាលមូលដ្ឋាន ដែលត្រូវបានបោះឆ្នោតជ្រើសរើស ពីព្រោះមន្ត្រីមូលដ្ឋានទាំងនោះនឹងពុំមានស្វ័យ័តភាពទេ ប្រសិនបើពួកគេមិនបានឆ្លើយតបទៅនឹងអ្នកបោះឆ្នោតមូលដ្ឋាន។

[3] កិច្ចតែងការបង្រៀនរបស់លោកសាស្ត្រាចារ្យ ឌៀក ពិដោរ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

[4] ក្រសួងផែនការ, ខែឧសភាឆ្នាំ២០០៩។

[5] USAID Center for democracy and governance, 2000.

[6] Samaratunge, Decentralization and Development, 1998.

តាមវាក្យស័ព្ទវិទ្យា ដែលកំណត់ក្នុងវិមជ្ឈការនៃប្រទេសកម្ពុជា ត្រូវបានចែកចេញជាវិមជ្ឈការ និងវិសហមជ្ឈការ។ ស័ព្ទវិមជ្ឈការត្រូវបានប្រើសំដៅលើកម្មវិធីវិមជ្ឈការនយោបាយដែលជាមួយគ្នានេះ រដ្ឋាភិបាលជាប់ឆ្នោតតាមលទ្ធិប្រជាធិបតេយ្យនឹងត្រូវបង្កើតឡើងនៅតាមថ្នាក់ឃុំ សង្កាត់(បណ្ឌិតដារីឧ អាយរ៉េស, ២០០១)[7]។

អត្ថន័យវិមជ្ឈការនៅកម្ពុជា ត្រូវបានប្រើយ៉ាងពេញនិយមក្នុងគោលនយោបាយផែនការយុទ្ធសាស្ត្រជាតិរបស់រាជរដ្ឋាភិបាល។ ការផ្តល់អត្ថន័យផ្សេងៗ ដែលបានផ្តល់គោលនយោបាយត្រីកោណ គោលនយោបាយចតុកោណជាដើម។ ពាក្យវិមជ្ឈការត្រូវបានសង្កត់ធ្ងន់ថា ការផ្ទេរសិទ្ធិអំណាច ការទទួលខុសត្រូវអោយក្លាយទៅជានីតិបុគ្គល និង បានសន្មត់ថា វិមជ្ឈការជាការផ្ទេរការទទួលខុសត្រូវក្នុងការរៀបចំផែនការ ការគ្រប់គ្រង និងហិរញ្ញវត្ថុពីរដ្ឋាភិបាលកណ្តាលអោយទៅ[8]៖

- អង្គភាពជំនាញរបស់ក្រសួងនៃរដ្ឋាភិបាលកណ្តាល
- អង្គភាពនៅក្រោមបង្គាប់ ឬកម្រិតនានានៃរដ្ឋាភិបាល
- ក្រុមហ៊ុន ឬអាជ្ញាធរសាធារណៈពាក់កណ្តាលស្វយ័ត
- រដ្ឋបាលមូលដ្ឋាន
- អង្គការឯកជននានា ឬវិស័យស្ម័គ្រចិត្ត។

សរុបមក វិមជ្ឈការ គឺជាមធ្យោបាយ ជាប្រព័ន្ធនៃការគ្រប់គ្រងរដ្ឋបាលមូលដ្ឋាន និង ជានយោបាយមួយរបស់រដ្ឋាភិបាលថ្នាក់ជាតិក្នុងការផ្ទេរសិទ្ធិ អំណាច ការទទួលខុសត្រូវ និង ប្រភពធនធានក្នុងកម្រិតណាមួយទៅអោយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការផ្ទេរស្វ័យ័តភាព និងអោយឃុំ សង្កាត់ក្នុងដែនដីរដ្ឋបាលរបស់ខ្លួនក្លាយទៅជានីតិបុគ្គល ក្នុងការធានាការឆ្លើយតបដោយចំពោះដល់ប្រជាពលរដ្ឋក្នុងដែនដីរបស់ខ្លួនទទួលបានសេវាកម្មជាសាធារណៈ និងមានកម្រិតជីវភាពល្អប្រសើរ ក្នុងតួនាទីភារកិច្ចជាអាណាព្យាបាល និង បម្រើប្រជាពលរដ្ឋ។

## III- មែកធាងវិមជ្ឈការ

វិមជ្ឈការ ជាធាតុចម្បងមួយក្នុងដំណើរការនៃការអនុវត្តការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់។ ក្រុមប្រឹក្សាឃុំ សង្កាត់ជានីតិបុគ្គលមួយដែលមានភារកិច្ចធានា និងអនុវត្តប្រព័ន្ធវិមជ្ឈការ។ តាមសៀវភៅរបស់លោកបណ្ឌិត ដារីឧ អាយរ៉េស(២០០១) បានចែកមែកធាងវិមជ្ឈការជាបួនសំខាន់ៗគឺ វិមជ្ឈការនយោបាយ វិមជ្ឈការរដ្ឋបាល វិមជ្ឈការសារពើពន្ធ និងវិមជ្ឈការសេដ្ឋកិច្ច/ ទីផ្សារ។ ក្នុងនេះ

[7] USAID Center for Democracy and Government, 2000.
[8] សៀវភៅរបស់លោកកៅ មុយថង ដែលបានសរសេរពី វិមជ្ឈការ និង វិសហមជ្ឈការ ឆ្នាំ២០០៧។

ដែរធាតុមួយក្នុងចំណោមមែកធាងទាំងបួនរបស់វិមជ្ឈការ គឺវិមជ្ឈការរដ្ឋបាលត្រូវបានចែកចេញជាបីទម្រង់គឺ វិសហមជ្ឈការ ការប្រគល់អំណាច និងការផ្ទេរអំណាចទាំងស្រុង។ មែកធាងដទៃទៀតរបស់វិមជ្ឈការ (ទាក់ទងផងដែរជាមួយប្រទេសកម្ពុជា) ត្រូវបានបង្ហាញនៅក្នុងតារាងទី២ ហើយត្រូវបានធ្វើការបកស្រាយដូចខាងក្រោម[9]៖

**តារាងទី២ ៖ មែកធាងនៃវិមជ្ឈការ**




## ១- វិមជ្ឈការនយោបាយ

វិមជ្ឈការនយោបាយ ជាខ្លឹមសារច្បាប់ស្ដីពី ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់និងច្បាប់ស្ដីពី ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ដែលផ្ដល់អោយប្រជាពលរដ្ឋ និងអ្នកទាំងឡាយដែលបានបោះឆ្នោតជ្រើសរើសធ្វើជាតំណាងរបស់ពួកគាត់(ប្រជាពលរដ្ឋ) នូវអំណាចច្រើនជាងមុនក្នុងការធ្វើសេចក្ដីសម្រេចចិត្តជាសាធារណៈ[10]។វិមជ្ឈការនយោបាយនេះហើយដែលUSAID ចង់សំដៅលើពេលដែលខ្លួនកំណត់និយមន័យវិមជ្ឈការ ហើយដែលរដ្ឋលេខាធិការក្រសួងមហាផ្ទៃ លោក ព្រំ សុខា ចង់និយាយពេលដែលលោកមានប្រសាសន៍ថា មានការយល់ដឹងកាន់តែច្រើនឡើងៗទូទាំងប្រទេសកម្ពុជាថា ប្រជាពលរដ្ឋត្រូវតែរួមចំណែកអោយកាន់តែខ្លាំងឡើងៗក្នុងការធ្វើសេចក្ដីសម្រេចចិត្តដែលទាក់ទងនឹងកិច្ចការរបស់ពួកគេ ដោយមានការយល់ដឹងច្រើនឡើងៗថា រដ្ឋាភិបាល និងការគ្រប់គ្រងរដ្ឋបាលត្រូវមានលក្ខណៈទន់ភ្លន់ និងឆ្លើយតបប្រសើរជាងមុនចំពោះប្រជាពលរដ្ឋ

[9] ប្រភព៖ វិមជ្ឈការ, (បណ្ឌិត ដារីត អាយរ៉េស, ខែសីហា ឆ្នាំ២០០១)។

[10] Rondinelli, What is Decentralization? World Bank Institute, 1999.

ហើយអាជ្ញាធរឃុំ ឬក្រុមប្រឹក្សាឃុំកាន់តែនៅជិតស្និទ្ធជាមួយប្រជាពលរដ្ឋ និងអាចធ្វើអន្តរាគមទាន់ពេលវេលាក្នុងការឆ្លើយតមសេចក្តីត្រូវការ។ ការបម្រើដល់ប្រយោជន៍ប្រជាពលរដ្ឋទៅបានគឺ ឆ្លងកាត់ការជ្រើសរើសពីប្រជាពលរដ្ឋ។

អ្នកទាំងឡាយ ដែលគាំទ្រវិមជ្ឍការនយោបាយបានធ្វើការអះអាងថា ការសម្រេចចិត្តដែលធ្វើអោយមានការចូលរួមច្រើនឡើងៗពីប្រជាពលរដ្ឋនឹងទទួលបានព័ត៌មាន និងការឆ្លើយតបប្រសើរជាងមុន ចំពោះស្ថានភាព និងតម្រូវការនៅមូលដ្ឋាន។

## ២- វិមជ្ឈការរដ្ឋបាល

វិមជ្ឈការរដ្ឋបាល គឺទាក់ទងទៅនឹងការបែងចែកឡើងនូវអំណាច ទំនួលខុសត្រូវ និងធនធានហិរញ្ញវត្ថុ សម្រាប់ផ្តល់សេវាកម្មសាធារណៈ ក្នុងចំណោមលំដាប់ថ្នាក់ផ្សេងៗនៃអង្គការចាត់តាំងរបស់រដ្ឋ។ ជាខ្លឹមសារ វាសំដៅលើការផ្ទេរទំនួលខុសត្រូវលើការរៀបចំផែនការហិរញ្ញវត្ថុ និងការចាត់ចែងមុខងារសាធារណៈខ្លះៗ ពីអំណាចរដ្ឋបាលកណ្តាល និងទីភ្នាក់ងាររបស់ខ្លួនទៅអង្គភាពមូលដ្ឋាន អង្គភាពក្រោមឱវាទ អាជ្ញាធរ ឬសាជីវកម្មសាធារណៈពាក់កណ្តាលស្វ័យ័ត។

តាម UNDP បានអោយនិយមន័យ វិមជ្ឈការរដ្ឋបាលថា ជាការផ្ទេរការទទួលខុសត្រូវក្នុងការរៀបចំផែនការ ការគ្រប់គ្រង និងការបែងចែកប្រភពថវិកាពីរដ្ឋាភិបាល និងភ្នាក់ងារផ្សេងៗរបស់ខ្លួនអោយទៅមូលដ្ឋាន អង្គភាពភ្នាក់ងារនៃរដ្ឋាភិបាលមូលដ្ឋាន អង្គភាពស្ថិតនៅក្រោមបង្គាប់រដ្ឋាភិបាល អាជ្ញាធរ ក្រុមហ៊ុនពាក់កណ្តាលស្វ័យ័ត អាជ្ញាធរមុខងារជាដើម។

លក្ខន្តិកៈគតិយុត្ត ឬទម្រង់ការរបស់រដ្ឋមានឥទ្ធិពលយ៉ាងខ្លាំង ទៅលើការរៀបចំអំណាចរដ្ឋបាលរបស់រដ្ឋនីមួយៗ។ ប្រទេសកម្ពុជា ជារដ្ឋទោល(Unilateral State) និង ជារាជាណាចក្រមួយដែលមិនអាចបំបែកបាន[11]។ ប្រការនេះវាមានផលវិបាកលើការរៀបចំអំណាចរដ្ឋបាល។ ក្នុងប្រទេសមួយដែលជារដ្ឋទោល មានភាពខុសគ្នាជាមួយរដ្ឋសហព័ន្ធនៅក្នុងរដ្ឋទោល រដ្ឋគ្មានដៃគូប្រជែងឡើយ គឺអំណាចទាំងអស់ត្រូវស្ថិតនៅក្នុងកណ្តាប់ដៃរបស់រដ្ឋ (អំណាចចេញបទបញ្ជា អំណាចផ្តាច់មុខរបស់រដ្ឋបាលកណ្តាល)។ ការគ្រប់គ្រងរដ្ឋបាលមិនតម្រូវអោយគេត្រូវតែប្រកាន់យកប្រព័ន្ធរដ្ឋបាលមជ្ឈការជាដាច់ខាតនោះទេ គេអាចធ្វើវិមជ្ឈការរដ្ឋបាលដោយមិនធ្វើអោយប៉ះពាល់ដល់ឯកភាពនយោបាយរបស់រដ្ឋដែរ ដោយបែងចែកអំណាចរដ្ឋបាលតាមប្រព័ន្ធគ្រប់គ្រងមជ្ឈការ(Centralization) វិមជ្ឈការ(Decentralization) និងវិសហមជ្ឈការ(Deconcentration)។សព្វថ្ងៃប្រទេសបារាំងបាន

[11] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ១៩៩៣។

អនុវត្តប្រព័ន្ធទាំងបីនេះជាមួយគ្នាតែម្តង។ យោលតាមកម្មវិធីកំណែទម្រង់ប្រព័ន្ធរដ្ឋបាល និងវិមជ្ឈការថ្នាក់ឃុំ សង្កាត់នៃប្រទេសកម្ពុជា ដែលបានធ្វើនៅថ្ងៃទី៣ ខែកុម្ភ: ឆ្នាំ២០០២នេះតទៅ សម្រាប់ថ្ងៃអនាគតប្រទេសកម្ពុជានឹងអនុវត្តប្រព័ន្ធទាំងបីនេះជាមួយគ្នាដែរ។ មានការលើកឡើងខុសៗគ្នាក្នុងការបែងចែកវិមជ្ឈការរដ្ឋបាល។ បើតាមសៀវភៅរបស់លោកបណ្ឌិត ដាវីឌ អាយរ៉េស(២០០១) បានបែងចែកវិមជ្ឈការរដ្ឋបាលជាបីប្រភេទសំខាន់ៗដូចខាងក្រោម៖

## ២.១- វិសហមជ្ឈការ

វិសហមជ្ឈការមានន័យថា រដ្ឋាភិបាល ក្រសួង ឬស្ថាប័នធ្វើប្រតិភូកម្ម(Delegation) មុខងារ សិទ្ធិ អំណាច និងធនធាន(ហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងបុគ្គលិក) ទៅអង្គភាពក្រោមបង្គាប់ឬទៅក្រុមប្រឹក្សាណាមួយ ដើម្បីអនុវត្តមុខងារក្នុងនាមរដ្ឋាភិបាល ក្រសួង ឬស្ថាប័ននោះ[12]។

ដោយយោងទៅលើអត្ថន័យវិមជ្ឈការ វិសហមជ្ឈការ គឺមានន័យផ្ទុយដោយថា មន្ត្រី និងធនធានត្រូវបានផ្ទេរពីថ្នាក់ជាតិ(ថ្នាក់កណ្តាល)ទៅកាន់ថ្នាក់ក្រោមជាតិ ប៉ុន្តែសិទ្ធិសម្រេចនៅថ្នាក់កណ្តាលដដែល[13]។

សញ្ញាណនៃវិសហមជ្ឈការ ជាបច្ចេកទេសមួយក្នុងការរៀបចំរដ្ឋបាល ដែលត្រូវបង្កើតឡើងដើម្បីកែសម្រួលប្រព័ន្ធមជ្ឈការ ហើយដែលបានផ្តល់ទៅអោយអាជ្ញាធរដែនដីនូវអំណាចសម្រេចសេចក្តីលើកិច្ចការខ្លះៗ ដែលជាធម្មតាអំណាចទាំងអស់នេះជារបស់រដ្ឋបាលកណ្តាលជាភ្នាក់ងារដែលទទួលបន្ទុកដឹកនាំអាជ្ញាធរដែនដី ដោយស្ថិតក្រោមអំណាចឋានានុក្រមនៃរដ្ឋបាលកណ្តាលដដែល។ មានការច្រឡំជាច្រើនចំពោះវិសហមជ្ឈការជាមួយវិមជ្ឈការនោះ ជាក់ស្តែងវិសហមជ្ឈការ មិនបានធ្វើអោយមានការផ្លាស់ប្តូរប្រព័ន្ធរដ្ឋបាលឡើយ វាគ្រាន់តែសម្រួលដល់ប្រព័ន្ធមជ្ឈការប៉ុណ្ណោះ ។

## ២.២- ការប្រគល់អំណាចឬប្រតិភូកម្ម

ការប្រគល់អំណាច គឺសំដៅទៅលើស្ថានភាពមួយដែលរដ្ឋបាលកណ្តាលផ្ទេរការទទួលខុសត្រូវលើការសម្រេចចិត្ត និងការគ្រប់គ្រងរដ្ឋបាលមុខងារសាធារណៈ ដែលធ្វើអោយរដ្ឋបាលមូលដ្ឋាន ឬ ជាអង្គភាពចាត់តាំងពាក់កណ្តាលស្វ័យ័ត ដែលមិន ត្រូវគ្រប់គ្រងទាំងស្រុងដោយរដ្ឋបាលកណ្តាល ប៉ុន្តែត្រូវរាយការណ៍ទៅអោយរដ្ឋបាលកណ្តាល។

---

[12] អង្គការពុទ្ធសាសនាដើម្បីការអភិវឌ្ឍន៍, ២០០៩។

[13] ក្រសួងផែនការ, ខែឧសភា ឆ្នាំ២០០៩។

រីឯការផ្ទេរអំណាចទាំងស្រុង ជារដ្ឋបាលស្វ័យ័តនៅថ្នាក់ក្រោមជាតិ ដូចជារដ្ឋបាលខេត្តស្រុក និងអាជ្ញាធរមូលដ្ឋានដែលត្រូវបានគេរៀបចំតាមច្បាប់ ជាការបែងចែកអង្គការអភិបាលកិច្ច។ ការផ្ទេរសិទ្ធិអំណាចទៅអង្គភាពរដ្ឋបាលខាងលើនេះ គឺជាទម្រង់ប្រគល់អំណាចទាំងស្រុងហើយជាការយល់ដឹងទូទៅថា ជាវិមជ្ឈការមិនក្លែងក្លាយ (Genuine Decentraliztation)។ តាមរយៈការប្រគល់អំណាចនេះរដ្ឋាភិបាលថ្នាក់ជាតិត្រូវធ្វើអនុប្បទាន(Relinquishment) មុខងារមួយចំនួនឬបង្កើតអង្គភាពថ្មីដែលមិនស្ថិតនៅក្រោមការត្រួតត្រាពីស្ថាប័នណាមួយ។ ភាពមិនក្លែងក្លាយនៃការធ្វើវិមជ្ឈការនេះ អាចត្រូវបានគេដឹងជាមូលដ្ឋានគ្រឹះមួយចំនួនដូចខាងក្រោមៈ

-ទី១ រដ្ឋាភិបាលមូលដ្ឋានមានសិទ្ធិអំណាចស្វ័យភាព ឯករាជ្យភាពក្នុងកិច្ចអភិវឌ្ឍន៍នៅមូលដ្ឋាន ឬរដ្ឋាភិបាលកណ្តាលមានការត្រួតពិនិត្យយ៉ាងតិចតួចkjnugកិច្ចការរដ្ឋបាលមូលដ្ឋាន។

-ទី២ រដ្ឋាភិបាលមូលដ្ឋាន ត្រូវបានគេទទួលស្គាល់ភាពត្រឹមត្រូវតាមច្បាប់ និងភាពច្បាស់លាស់នូវព្រំប្រទល់ភូមិសាស្ត្រដែលខ្លួនបំពេញមុខងារ និងដែនសមត្ថភាពរបស់ខ្លួន។

-ទី៣ រដ្ឋាភិបាលមូលដ្ឋានមានលក្ខន្តិកៈបែបក្រុមហ៊ុន និងសិទ្ធិអំណាចក្នុងការរក្សាប្រភពធនធានផ្សេងៗ ដើម្បីបំពេញមុខងាររបស់ខ្លួន។

-ទី៤ ដើម្បីអភិវឌ្ឍន៍ រដ្ឋាភិបាលមូលដ្ឋានចាំបាច់ ត្រូវធ្វើអនុលោមតាមការប្រគល់អំណាចទាំងស្រុង(Devolution)ជាស្ថាប័នក្នុងន័យថា ប្រជាពលរដ្ឋ ជាអ្នកត្រួតពិនិត្យមើលអង្គការដែលជាអ្នកផ្តល់សេវាសាធារណៈ តាមសេចក្តីត្រូវការ និងចង់បានរបស់ពួកគេ ហើយជាថ្នាក់រដ្ឋាភិបាលមួយដែលមានឥទ្ធិពលមួយចំនួន។

- ទី៥ ការប្រគល់អំណាចទាំងស្រុង ជារបៀបនៃការគ្រប់គ្រងមួយដែលរដ្ឋាភិបាលនៅមូលដ្ឋាន និងរដ្ឋាភិបាលថ្នាក់ជាតិទទួលបាននូវអត្ថប្រយោជន៍ពីគ្នាទៅវិញទៅមក និងមានការសម្របសម្រួលគ្នា។

ការផ្ទេរអំណាចទាំងស្រុង ជាទម្រង់ធំជាងគេរបស់វិមជ្ឈការ គឺសំដៅទៅលើស្ថានភាពមួយដែលរដ្ឋាភិបាលកណ្តាលបានផ្ទេរអំណាចក្នុងការសម្រេចចិត្តហិរញ្ញវត្ថុ និងការចាត់ចែងទៅអោយអង្គភាពដែលស្ទើរតែស្វ័យ័តនៃរដ្ឋបាលមូលដ្ឋាន។

## ៣- វិមជ្ឈការសារពើពន្ធ

ការទទួលខុសត្រូវខាងសារពើពន្ធ ជាធាតុផ្សំមួយយ៉ាងសំខាន់បំផុតនៃវិមជ្ឈការ ព្រោះរដ្ឋបាលមូលដ្ឋានត្រូវតែមានចំណូលគ្រប់គ្រាន់ (ដែលប្រមូលបាននៅមូលដ្ឋានផ្ទាល់ ឬបញ្ជូនពីរដ្ឋបាលកណ្តាល) ដើម្បីធ្វើការសម្រេចចិត្តលើការចំណាយសេវាកម្មនានារបស់ឃុំ សង្កាត់របស់ខ្លួន។ វិមជ្ឈការសារពើពន្ធមានទម្រង់ជាច្រើនដែលអាចត្រូវបានសង្ខេបដូចខាងក្រោមៈ

- ហិរញ្ញប្បទានផ្ទាល់ខ្លួន ឬការទូទាត់ចំណាយតាមការយកថ្លៃពីអ្នកប្រើប្រាស់។
- ការពង្រីកប្រាក់ចំណូលក្នុងមូលដ្ឋាន តាមរយៈការយកពន្ធអាករ និងការយកថ្លៃសេវាកម្មដោយប្រយោល។
- ការផ្ទេរហិរញ្ញប្បទានដែលមានលក្ខណៈអន្តររដ្ឋបាល។
- ការផ្តល់អំណាចក្នុងការខ្ចីហិរញ្ញប្បទាន ដើម្បីបម្រើមូលដ្ឋាន[14]។

### ៤- វិមជ្ឈការសេដ្ឋកិច្ច ឬទីផ្សារ

ចេញពីចក្ខុវិស័យរបស់រដ្ឋាភិបាលវិមជ្ឈការសេដ្ឋកិច្ច ឬទីផ្សារ ជាធម្មតាជាទម្រង់ពេញលេញបំផុតរបស់វិមជ្ឈការ ព្រោះវាផ្ទេរការទទួលខុសត្រូវលើមុខងារផ្សេងៗពីផ្នែករដ្ឋទៅផ្នែកឯកជន។ ជាញឹកញាប់ វិមជ្ឈការសេដ្ឋកិច្ចកើតឡើង តាមរយៈឯកជនភាវូបនីយកម្ម និងការកាត់បន្ថយនីយ័តកម្មមួយឬបន្សុំគ្នា[15]។

## IV- ទំហំនៃវិមជ្ឈការ និងវិសហមជ្ឈការដែលរៀបចំនៅកម្ពុជា

### ១- ទំហំវិមជ្ឈការ

ដើម្បីអនុវត្តប្រព័ន្ធគ្រប់គ្រងរដ្ឋបាលតាមបែបវិមជ្ឈការ ក្រសួងមហាផ្ទៃបានរៀបចំច្បាប់ពីរដែលមានទំនាក់ទំនងផ្សាភ្ជាប់គ្នា គឺច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ដែលបានអនុម័តនៅថ្ងៃទី១២ ខែមករា ឆ្នាំ២០០១ ហើយត្រូវបានប្រកាសអោយប្រើនៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់បានអនុម័តនៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០០១ ហើយត្រូវបានប្រកាសអោយប្រើនៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១។ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ គឺជាការបង្ហាញនូវគំនិត និងទំហំវិមជ្ឈការនៅកម្ពុជា។ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ គឺជាការកម្រិតនៃបែបបទ និងនីតិវិធីក្នុងការបោះឆ្នោតក្នុងលក្ខខណ្ឌសេរី ត្រឹមត្រូវ យុត្តិធម៌ និងឈរលើគោលការណ៍ប្រជាធិបតេយ្យសេរីពហុបក្ស។

ដំណើរការវិមជ្ឈការ ត្រូវបានរៀបចំបង្កើតដោយមានអាជ្ញាធរមូលដ្ឋាននៅក្នុងឃុំ សង្កាត់នីមួយៗដែលខុសពីរដ្ឋបាលថ្នាក់ជាតិ និងដឹកនាំដោយតំណាងឃុំ សង្កាត់ដែលជាប់ឆ្នោត ដើម្បីអនុវត្តដែនសមត្ថកិច្ចរបស់ខ្លួន ក្នុងក្របខណ្ឌឃុំ សង្កាត់។ នៅក្នុងដំណើរការឃុំ សង្កាត់ចាំបាច់ត្រូវការទំនាក់ទំនងជាមួយរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល ដើម្បីបណ្តុះបណ្តាលធនធានសមាជិក

[14] Rondinelli, What is Decentralization? World Bank Institute, 1999.
[15] Rondinelli, What is Decentralization? World Bank Institute, 1999.

ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការរៀបចំកសាងផែនការអភិវឌ្ឍន៍មូលដ្ឋាន និង ថវិកាឃុំ សង្កាត់អោយមានការទទួលខុសត្រូវ តម្លាភាព និង អភិបាលកិច្ចល្អ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល[16]។

## ២- ទំហំវិសហមជ្ឈការ

វិសហមជ្ឈការនៅថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌ តម្រូវអោយមានការសិក្សាពិចារណារៀបចំឡើងវិញនូវរចនាសម្ព័ន្ធមួយចំនួន និងប្រព័ន្ធរដ្ឋបាលថ្នាក់គ្រប់ជាន់ថ្នាក់ តាមគោលការណ៍វិសហមជ្ឈការរដ្ឋបាល។ ក្រសួងមហាផ្ទៃផ្តល់សិទ្ធិ និងទំនួលខុសត្រូវដល់អភិបាលខេត្ត ក្រុង ដើម្បីគាំទ្រក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការត្រួតពិនិត្យប្រតិបត្តិការរបស់ក្រុមប្រឹក្សាឃុំ សង្កាត់អភិបាលខេត្ត ក្រុងត្រូវធានាថា មន្ទីរនានាត្រូវផ្តល់ការគាំទ្រ និងការណែនាំដល់ក្រុមប្រឹក្សាឃុំ សង្កាត់។

ខេត្ត ក្រុង និងស្រុក ខណ្ឌត្រូវស្ថិតនៅថ្នាក់គ្រប់គ្រងរដ្ឋបាលមួយដែលមានតួនាទីក្នុងការផ្សាភ្ជាប់ទំនាក់ទំនងរវាងរដ្ឋបាល ថ្នាក់ជាតិទៅនឹងថ្នាក់ឃុំ សង្កាត់ដែលជាអ្នកគ្រប់គ្រងតាមបែបវិមជ្ឈ ការ។

ខេត្ត ក្រុង និងស្រុក ខណ្ឌត្រូវតែមានការរៀបចំកែតម្រូវការគ្រប់គ្រងរដ្ឋបាលរបស់ខ្លួន ក្នុងការពង្រឹងការទទួលខុសត្រូវ ដើម្បីអោយរដ្ឋាភិបាលមានកម្លាំង និងមានសមត្ថភាពគ្រប់គ្រាន់សម្រាប់ជួយឧបត្ថម្ភគាំទ្រខាងធនធានមនុស្ស ធនធានបច្ចេកទេស ធនធានរដ្ឋបាល តាមរយៈថ្នាក់រដ្ឋបាលខេត្ត ក្រុង និងស្រុក ខណ្ឌទៅអោយឃុំ សង្កាត់ដែលកំពុងតែអនុវត្តនយោបាយវិមជ្ឈការ។ រដ្ឋាភិបាលធ្វើដូចនេះ ដោយយល់ឃើញថា នៅក្នុងតំណាក់ការកសាងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលវិមជ្ឈការនៅថ្នាក់ឃុំ សង្កាត់នេះ គឺអ្វីដែលចាប់ផ្តើមឡើងសុទ្ធថ្មីទាំងអស់ ពោលគឺក្រុមប្រឹក្សាឃុំ សង្កាត់ដែលកើតចេញពីការបោះឆ្នោតសុទ្ធសឹងតែមនុស្សថ្មីការដឹកនាំ ដោយឡែកការកសាងនូវការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមប្រព័ន្ធវិមជ្ឈការ ក៏ជាប្រព័ន្ធគ្រប់គ្រងដែលថ្មីស្រឡាងដែរ។ នៅក្នុងស្ថានភាពនេះ ប្រសិនបើខេត្ត ក្រុង និងស្រុក ខណ្ឌមានកម្លាំង និងមានសមត្ថភាពគ្រប់គ្រាន់សម្រាប់ជួយឧបត្ថម្ភគាំទ្រនោះទេ ការគ្រប់គ្រងរបស់ឃុំ សង្កាត់ប្រាកដជាជួបការលំបាកជាមិនខាន។

ខេត្ត ក្រុង និងស្រុក ខណ្ឌដែលរដ្ឋបាលរៀបចំតាមវិសហមជ្ឈការ គឺធ្វើឡើងដើម្បីអោយថ្នាក់រដ្ឋបាលទាំងពីរនេះនឹងយកសេវាកម្មនានារបស់រដ្ឋ ទៅបម្រើប្រជាពលរដ្ឋបានឆាប់រហ័ស និងមានប្រសិទ្ធភាព។ ប្រព័ន្ធវិមជ្ឈការនេះគឺជាការបង្កលក្ខណៈសម្បត្តិថ្មីមួយ ក្នុងការអនុវត្តកិច្ចការ

[16] សន គីណាល់,កម្មវិធីសិលា(វិមជ្ឈការនៅកម្ពុជា), ២០០២។

ទាំងឡាយ ដែលលំបាកស្មុគស្មាញខ្លាំង ហើយថ្នាក់រដ្ឋបាលឃុំ សង្កាត់មិនអាចអនុវត្តបានល្អប្រសើរ ក្នុងការផ្គត់ផ្គង់សេចក្តីត្រូវការរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋានរដ្ឋបាលរបស់ខ្លួន[17]។

## V- លក្ខខណ្ឌវិមជ្ឈការប្រកបដោយជោគជ័យ

វិមជ្ឈការនៅទីនេះមានន័យថា គឺជាវិមជ្ឈការរដ្ឋបាលផង និងជាវិមជ្ឈការនយោបាយផងឬវិសហាមជ្ឈការ និងវិមជ្ឈការផងដែរ ដែលវាក្យស័ព្ទទាំងនេះត្រូវបានប្រើដោយរាជរដ្ឋាភិបាលកម្ពុជា។ ជាលទ្ធផលមានទាំងលទ្ធផលជោគជ័យ និងបរាជ័យក្នុងតំបន់ និងប្រទេសផ្សេងៗគ្នាសូម្បីក្នុងរង្វង់ប្រទេសតែមួយក៏ដោយ។ តាមការលើកឡើងពីវិមជ្ឈការនេះ ធ្វើអោយកាន់តែច្បាស់ថា ការអនុម័តកម្មវិធីវិមជ្ឈការដោយរដ្ឋាភិបាលវាស្ថិតនៅឆ្ងាយពីការធានាថាកម្មវិធីនោះ នឹងនាំមកនូវលទ្ធផលដ៏ជោគជ័យ។ តាមបណ្តាប្រទេសកំពុងអភិវឌ្ឍន៍នានា វាជាឧទាហរណ៍មួយដែលរដ្ឋាភិបាលរបស់ពួកគេទំនងជាមានការប្តេជ្ញាចិត្តពិតប្រាកដ ក្នុងការអនុវត្តវិមជ្ឈការប៉ុន្តែបទពិសោធន៍នៃវិមជ្ឈការចុងក្រោយរបស់ពួកគេ គឺស្ថិតនៅឆ្ងាយពីជោគជ័យទាំងស្រុង។

មានការលើកឡើងច្រើនពីលក្ខខណ្ឌចាំបាច់ សម្រាប់វិមជ្ឈការប្រកបដោយជោគជ័យ។ ច្បាស់ណាស់ថា លក្ខខណ្ឌចាំបាច់ គឺស្ថិតលើការជំទាស់ដោយមានហេតុផល ឬអំណះអំណាងដែលទាមទារអោយបកស្រាយច្បាស់លាស់ផងដែរ។ លោក Livack បានលើកឡើងនូវចំណុចសំខាន់ថា ភាគច្រើននៃការលើកឡើងពីវិមជ្ឈការមានមូលដ្ឋានលើប្រទេសឧស្សាហកម្ម ប៉ុន្តែត្រូវបានប្រើវាក្នុងអត្ថិភាពនៃស្ថាប័នផ្សេងៗដែលមានលក្ខណៈទន់ខ្សោយក្នុងប្រទេសកំពុងអភិវឌ្ឍន៍ទៅវិញ។

តាមការលើកឡើងរបស់លោក Livack ថាហិរញ្ញវត្ថុសាធារណៈដែលទាក់ទងទៅនឹងវិមជ្ឈការសារពើពន្ធពឹងផ្អែកទៅលើសម្លេងគាំទ្រ និងសម្លេងមិនគាំទ្រ ដើម្បីធានាទំនួលខុសត្រូវនៅក្នុងមូលដ្ឋាន។ បើយោងតាមទស្សនៈនេះ ប្រសិនបើប្រជាពលរដ្ឋមិនសប្បាយចិត្តនឹងការសម្រេចចិត្តរបស់អ្នកដឹកនាំមូលដ្ឋានទេ ពួកគាត់មានសិទ្ធិអាចបោះឆ្នោតទម្លាក់ចេញពីអំណាចបាន។ បើពួកគេមិនពេញចិត្តកាតព្វកិច្ចពន្ធអាករមូលដ្ឋាន និងសេវាសាធារណៈដែលត្រូវបានផ្តល់អោយពួកគេនោះ អាចមិនទទួលយកតាមនីតិវិធីដែលធ្វើអោយពួកគេស្ងប់ចិត្តបាន[18]។

ទោះជាមានបញ្ហាកំហិតទាំងនេះក្នុងចិត្តក៏ដោយលោក Parker បានធ្វើការអះអាងថាមានលក្ខខណ្ឌជាច្រើនដែលអាចដឹងបាន ហើយអាចពង្រីកនូវឱកាសសម្រាប់វិមជ្ឈការប្រកបដោយ

---

[17] សន គីណាល់, កម្មវិធីសិលា(វិមជ្ឈការនៅកម្ពុជា), ២០០២។

[18] Litvack, Rethinking Decentralization in Developing Countries, World Bank, 1998.

ជោគជ័យ[19]។ យោងទៅតាមលក្ខខណ្ឌជោគជ័យដែលបានចែងខាងក្រោមនេះក្រុម ប្រឹក្សាឃុំសង្កាត់ដែលត្រូវចូលរួមយ៉ាងសកម្ម និងមានឆន្ទះខ្ពស់ក្នុងការអនុវត្តនយោបាយវិមជ្ឈការជាមួយរដ្ឋាភិបាល និងគិតគូរដល់ប្រយោជន៍ប្រជាពលរដ្ឋក្នុងមូលដ្ឋានរបស់ខ្លួនជាចម្បង ដើម្បីធ្វើអោយទទួលបាននូវប្រសិទ្ធភាពខ្ពស់ (ការអនុវត្តនយោបាយវិមជ្ឈការ) ដែលនឹងអាចកាត់បន្ថយបាននូវការប្រឈមដែលកើតមានឡើង ដោយលក្ខខណ្ឌមិនសមស្របណាមួយ។

## ១- ក្របខណ្ឌច្បាប់ដែលត្រូវបង្កើតឡើងច្បាស់លាស់

ការរៀបចំក្របខណ្ឌច្បាប់នេះ គួរតែកំណត់ន័យអំពីស្ថាប័នវិមជ្ឈការ និងកំណត់អោយបានច្បាស់លាស់ពីរបៀបនៃការបង្កើតស្ថាប័ន ព្រមទាំងរបៀបដែលពួកគេទំនាក់ទំនងគ្នាជាមួយស្ថាប័នដទៃទៀត។ លោក Parker បានលើកឡើងថា ប្រសិនបើការចាត់ចែងរៀបចំស្ថាប័នដែលមានពីមុនអាចត្រូវបានកែសម្រួលយ៉ាងសមរម្យ កិច្ចការនៃការបង្កើតក្របខណ្ឌច្បាប់ ទំនងជាមានភាពស្មុំញាំតិចជាងពេលដែលស្ថាប័នថ្មីស្រឡាងកំពុងត្រូវបានបង្កើតឡើង។

តាមធនាគារអភិវឌ្ឍន៍អាស៊ី ដែលហៅកាត់ថា ADB (១៩៩៥) បានអះអាងថាគោលដៅសំខាន់នៃក្របខណ្ឌនិយ័តកម្ម និងច្បាប់ ដើម្បីផ្តល់នូវភាពអាចទាយទុកជាមុនបាន។ ការលើកឡើងនេះមិនត្រឹមតែជួយកំណត់អោយបានច្បាស់លាស់នូវកាតព្វកិច្ច និងសិទ្ធិប៉ុណ្ណោះទេ តែថែមទាំងជួយសម្រួលបរិស្ថានសេដ្ឋកិច្ចអោយមានសណ្តាប់ធ្នាប់ និងមានភាពប្រសើរឡើងថែមទៀតផង។

## ២- ស្ថាប័នប្រកបដោយសមត្ថភាព

ស្ថាប័នដែលបានទទួលវិមជ្ឈការរួចហើយ ត្រូវមានសមត្ថភាពអនុវត្តអំណាច និងការទទួលខុសត្រូវដែលថ្នាក់លើប្រគល់អោយ។ ក្នុងបរិបទនៃការអភិវឌ្ឍន៍ជនបទដែលមានភាពទាក់ទងយ៉ាងច្បាស់ជាមួយប្រទេសកម្ពុជា ដែលសមត្ថភាពនេះមានន័យថា អាចមានលទ្ធភាពធ្វើកិច្ចការ និងជម្រុញការផ្តល់សេវាកម្មអោយកាន់តែល្អយ៉ាងពិតប្រាកដ។ តាមទស្សនៈរបស់លោក Parker ការខ្វះសមត្ថភាពអាចត្រូវបានឆ្លុះបញ្ចាំងនៅក្នុងចំណុចមួយក្នុងបណ្តាចំណុចខាងក្រោមៈ

- ការផ្តល់មូលនិធិមិនគ្រប់គ្រាន់ក្នុងការឆ្លើយតបទៅនឹងស្តង់ដាអប្បបរិមានៃសេវាកម្មនិងការផ្គត់ផ្គង់ផ្សេងៗទៀត។
- អសមត្ថភាពក្នុងការប្រមូលធនធានហិរញ្ញវត្ថុដែលមាន។
- ភាពបរាជ័យក្នុងការផ្តល់ទំនិញ និងសេវាកម្មនានាដោយចំណាយតិចបំផុត។

[19] Parker, The Way Forward for Rural Development, World Bank, 1997.

- បន្ទុំមិនសមរម្យនៃសេវាកម្មនានា ធៀបទៅនឹងចំណូលចិត្តរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន។

## ៣- ប្រព័ន្ធគណនេយ្យភាព (ទំនួលខុសត្រូវ)

តាមការសិក្សាបានមើលឃើញយ៉ាងតិចតួច ក្នុងការបើកទូលាយនូវសកម្មភាពនានារបស់រដ្ឋបាលមូលដ្ឋាន ដែលពេលខ្លះសកម្មភាពមួយចំនួន គឺគ្មានគណនេយ្យភាពទេដោយសារតែព័ត៌មានមិនត្រូវបានទម្លាយជាសាធារណៈ។

អំណះអំណាងជាមូលដ្ឋានមួយ ក្នុងចំណោមអំណះអំណាងដទៃទៀតដែលគាំទ្រដល់វិមជ្ឈការ គឺការបង្កើតការទទួលខុសត្រូវ។ ហេតុផលគឺសាមញ្ញបំផុតអង្គភាពរដ្ឋបាលមូលដ្ឋានស្ថិតនៅយ៉ាងជិតជាមួយប្រជាពលរដ្ឋ ដែលជាលក្ខណៈងាយស្រួលមួយអាច ត្រួតពិនិត្យរាល់សកម្មភាពរបស់ពួកគេបានយ៉ាងងាយស្រួល។ តាមលោក Klugman បានលើកទស្សនៈថាការមិនទទួលខុសត្រូវ ឬការខ្វះការទទួលខុសត្រូវរបស់មន្ត្រីរដ្ឋបាលមូលដ្ឋានមិនទំនងជាស្ថិតនៅក្នុងប្រព័ន្ធវិមជ្ឈការមួយ ដែលលក្ខខណ្ឌខ្លះក្នុងចំណោមលក្ខខណ្ឌខាងក្រោមត្រូវបានបំពេញ៖

- ចូលរួមយ៉ាងសកម្មដោយប្រជាពលរដ្ឋមូលដ្ឋានក្នុងការពិភាក្សា និងសម្រេចចិត្តរបស់ រដ្ឋបាលមូលដ្ឋាន។
- ទម្រង់ការ និងរបាយការណ៍គណនេយ្យភាពដែលមានភាពទៀងទាត់ សាមញ្ញ ច្បាស់លាស់ និងមានលក្ខណៈបើកចំហ។
- យ៉ាងហោចណាស់កម្រិតជាមូលដ្ឋានមួយមានការយល់ដឹងពីការ គណនានព្វន្ត ការអាន និងការសរសេរនៅក្នុងសហគមន៍។
- វិធីខ្លះៗនៃគណនេយ្យភាព អ្នកមិនទទួលខុសត្រូវ មិនត្រូវបានទទួលទោស ឬទទួលទណ្ឌកម្ម។ ឧទាហរណ៍៖ តាមរយៈការបោះឆ្នោតទម្លាក់ និងសិទ្ធិរបស់ប្រជាពលរដ្ឋអាចប្តឹងទៅតុលាការ ដោយចំណាយប្រាក់តិចតួចតែប្រកបដោយប្រសិទ្ធភាព ដើម្បីធានាដំណើរការអោយបានសមរម្យ និងទំនួលខុសត្រូវជាសាធារណៈ[20]។

លោក Ford បានលើកឡើងថា ប្រព័ន្ធនៃការទទួលខុសត្រូវ ត្រូវតែមានមូលដ្ឋានទៅលើព័ត៌មានជាសាធារណៈប្រកបដោយតម្លាភាព ដែលអាចអនុញ្ញាតអោយសហគមន៍ទាំងមូលត្រួតពិនិត្យមើលទង្វើរដ្ឋបាលមូលដ្ឋាន និងមន្ត្រីមូលដ្ឋានមានទឹកចិត្តឆ្លើយតបទៅនឹងទង្វើនោះ។

[20] Klugman, Decentralisation, UNDP, 1994.

## ៤- សង្គមស៊ីវិលសកម្ម

លោក Parker ប្រកាសថាសង្គមស៊ីវិលសកម្មមួយ ទំនងជាជួយបានយ៉ាងច្រើនក្នុងការអនុវត្តវិមជ្ឈការ[21]។ រីឯលោក Azfar យល់ស្របជាមួយទស្សនៈនេះដោយលោកលើកឡើងថា អង្គការមិនមែនរដ្ឋាភិបាល សមាគមអ្នកប្រើប្រាស់ និងក្រុមសង្គមស៊ីវិលដទៃទៀត អាចសម្របសម្រួលសកម្មភាពរបស់ប្រជាពលរដ្ឋ និងអាចពាំនាំសម្លេងរបស់ពួកគេទៅអោយរដ្ឋាភិបាល។លើសពីនេះទៀតនោះ ពួកគេអាចដើរតួផងដែរជាអ្នកត្រួតពិនិត្យលើសកម្មភាពរបស់រដ្ឋាភិបាល និងជម្រុញអោយអ្នកដឹកនាំគោរពបំណងប្រាថ្នារបស់ប្រជាពលរដ្ឋ[22]។

បើតាមទស្សនៈរបស់លោក Manor លោកក៏ព្យាយាមគាំទ្រនូវអំណះអំណាងរបស់លោក Parker ដែលទាក់ទងទៅនឹងសង្គមស៊ីវិលផងដែរ។ លោកបានបង្ហាញថា នៅពេលសង្គមស៊ីវិលរស់រវើកមួយកើតឡើងមានមន្ទិលសង្ស័យតិចតួចប៉ុណ្ណោះដែលថាជានិច្ចកាល សង្គមស៊ីវិលពិតជាអាចជួយដល់អាជ្ញាធរមូលដ្ឋានក្នុងការធ្វើការងារអោយប្រសើរបានមែន[23]។ ចំពោះអំណះអំណាងដែលមានការសង្ស័យថា តើវិមជ្ឈការអាចទទួលបានសមិទ្ធផលជារូបរាងបានទេ ចំពោះការអវត្តមានរបស់សង្គមស៊ីវិលនោះ។ លោក Manor បានបង្ហាញនូវចំណុចបួនសំខាន់ៗដែលបានបញ្ជាក់សកម្មភាពដ៏សកម្ម និងកិច្ចអភិវឌ្ឍន៍របស់សង្គមស៊ីវិល។ ខាងក្រោមនេះជាចំណុចសំខាន់ៗទាំងបួនដែលលោក Manor បានលើកឡើង៖

១- នៅពេលដែលអាជ្ញាធកម្រិតថ្នាក់ក្រោម ត្រូវបានបង្កើតឡើងនូវសមាជិកភាពរបស់ពួកគេដោយប្រឹងប្រែងបញ្ចេញសកម្មភាពយ៉ាងសកម្ម ដើម្បីបំពេញភារកិច្ចដែលពួកគេគិតថានោះជាអ្វីដែលអ្នកបោះឆ្នោតអោយដល់ពួកគេ(មិនថាមានសង្គមស៊ីវិលដ៏សកម្ម ឬអត់នោះទេ)។

២- អ្នកតំណាងដែលជាប់ក្នុងការបោះឆ្នោត នៅពេលចូលកាន់តំណែងដំបូងមិនត្រូវការការបង្រៀនពីសង្គមស៊ីវិលទេ ដើម្បីយល់ដឹងថាពួកគេត្រូវមានជំនឿជាក់លើខ្លួនឯងក្នុងការដោះស្រាយបញ្ហាជាមួយមន្ត្រីការិយាធិបតេយ្យ។ លោក Manor យល់ថាបញ្ហាក្នុងដំណាក់កាលដំបូងជាធម្មតា គឺថាអ្នកតំណាងតែងតែបញ្ចេញសកម្មភាពទាំងហួសហេតុពេកដោយមិនសម្របខ្លួនទៅរកមន្ត្រីការិយាធិបតេយ្យឡើយ។

៣- យើងត្រូវការពិចារណាស្ថានភាពដែលសកម្មភាពទាំងនោះកើតឡើង មុនពេលមានវិមជ្ឈការ ដែលមន្ត្រីការិយាល័យស្ទើរតែមិនបានឆ្លើយតប ឬយល់ដឹងតិចតួចពីគំនិតក្រុមផ្សេងៗក្នុងមូលដ្ឋានជាងពេលដែលមានវិមជ្ឈការ។ ដូចនេះ ដំណាក់កាលទីមួយបន្ទាប់ពីមានវិមជ្ឈការការ

---

[21] Parker,The Way Forward for Rural Development, World Bank, 1997.
[22] Azfar , Decentralization, Governance and Public Service, 1999.
[23] Manor, Promise and Limitations of Decentralization, 1997.

បង្កើតស្ថាប័នតំណាងតែឯង ល្មមគ្រប់គ្រាន់អោយប្រព័ន្ធថ្មីដំណើរការដែលអាចទទួលយកបាន ទោះបីអវត្តមានរបស់សង្គមស៊ីវិលក៏ដោយ។

៤- ឥទ្ធិពលចិត្តអាចនាំអោយមានការចូលរួម និងសកម្មភាពកាន់តែមានច្រើនជាងមុនក្នុងចំណោមមហាជនថ្នាក់ក្រោមដូច្នេះសង្គមស៊ីវិលគួរតែចាប់ផ្តើមដើរតួនាទីច្នៃប្រឌិតយ៉ាងឆាប់រហ័សក្នុងប្រព័ន្ធនេះ[24]។

## VI- ប្រវត្តិនិងការអនុវត្តប្រព័ន្ធវិមជ្ឈការនៅកម្ពុជា

ប្រព័ន្ធវិមជ្ឈការ ត្រូវបានអនុវត្តជាយូរលង់ណាស់មកហើយ នៅបណ្តាប្រទេសអឺរ៉ុបដូចជាប្រទេសបារាំងជាដើម។ ក្នុងប្រព័ន្ធវិមជ្ឈការជាដំបូងគេផ្តល់អោយឃុំ សង្កាត់ជានីតិបុគ្គលមានស្វ័យភាពហិរញ្ញវត្ថុទើបគេហៅថា វិមជ្ឈការ ដែលត្រូវបានគេដឹងថាជាអភិបាលកិច្ចមូលដ្ឋាន (Local Governance)។ នៅប្រទេសបារាំង នីតិបុគ្គលនៃឃុំ សង្កាត់ គេបានបង្កើតអោយមានជាវិមជ្ឈការរដ្ឋបាលដែនដី (Territorial Adminstriation Decentralization) ក្រុមប្រឹក្សាអភិបាលកិច្ច (Local Governance Council) នាយកប្រតិបត្តិ (Executive Chief) ដែលគេហៅថា "Mayor" រីឯនៅប្រទេសកម្ពុជាគេហៅថាមេឃុំ ឬចៅសង្កាត់ "Commune/ Sangkat Chief"។

បើតាមឯកសារប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជាបានបង្ហាញថា ការរៀបចំការគ្រប់គ្រងរដ្ឋបាលគឺមានកំណើតឡើងចាប់តាំងពីថ្ងៃកកើតទឹកដីមកម្លេះ ដោយផ្អែកតាមរបបរាជានិយម ដែលការបង្កើតច្បាប់នោះ គឺគ្មានលក្ខខណ្ឌច្បាស់លាស់ទេ (គ្មានលក្ខណៈសរសេរចងក្រង ជាច្បាប់)។ ព្រះមហាក្សត្រទ្រង់មាននាទីជាប្រមុខរដ្ឋបាលតុលាការនិងជាអ្នកដឹកនាំចម្បាំង[25]។

-ដើមសតវត្សទី១ កម្ពុជាអនុវត្តរបបគ្រប់គ្រងជាសហគមន៍មូលដ្ឋានមានក្របខណ្ឌភូមិសាស្ត្រជាស្រុកភូមិរួមក្នុងអំបូរខ្មែរមន។

-សតវត្សទី៩-១១ ក្រោយពីរំដោះប្រទេសពីជ្វាមក ពេលនោះប្រទេសខ្មែរគោរពបូជាព្រះអាទិទេពនៃលទ្ធិទេវរាជ។ ការគ្រប់គ្រងរដ្ឋតាមបែបមជ្ឈការសហគមន៍មូលដ្ឋានត្រូវបាត់បង់នូវឯករាជ្យភាពរបស់ខ្លួន ហើយក៏រលាយខ្លួនទៅជារដ្ឋពុំមានក្រុម ឬសហគមន៍ទៀតឡើយជាហេតុធ្វើអោយចាមវាយយកអង្គរ(ក្រុងអង្គរ) បាននៅឆ្នាំ១១៧៧។

-សតវត្សទី១៧ដែនដីរដ្ឋចែកជាដីភូមិភាគ ដែលមានមន្ត្រីម្នាក់ទទួលខុសត្រូវលើភូមិភាគនីមួយៗដោយមាន"មឿង"ជាអ្នកកាន់កាប់លើដែនដី ជាស្តេចត្រាញក្នុងនាមព្រះមហាក្សត្រដែល នៅក្នុងសម័យនោះគេមិនប្រើពាក្យ"ខេត្ត"ទេ។ រហូតមកដល់ជំនាន់ស្តេចអង្គឌួងពាក្យ"មឿង" នេះ ត្រូវ

[24] Manor, Promise and Limitations of Decentralization, 1997.

[25] កំណត់ហេតុ ជីវតាក្វាន់, ឆ្នាំ១២៩៦។

បានប្តូរមកជាខេត្តវិញដោយសារពាក្យ "មឿង" ជាភាសាដែលសៀមធ្លាប់បានប្រើ។ ក្នុងសម័យបូរាណមណ្ឌលរដ្ឋបាលគេហៅថា "ដី" ដែលជំនាន់នោះ "ដី" របស់ស្តេចត្រាញមានទំហំធំជាង "តំបន់" របស់សាធារណៈរដ្ឋខ្មែរ[26]។ រីឯស្រុក ជាឈ្មោះ "ភូមិកំណើត" របស់នរណាម្នាក់ដែលឥឡូវនេះគេហៅថា "ឃុំ"។ ពួកចាស់ៗជំនុំគ្នាហៅថា "ក្រុមជំនុំ" ហើយតែងតាំងក្មេងៗដែល មានភាពឈ្លាសវៃអោយធ្វើការហៅថា "មេស្រុក"។ ក្រុមជំនុំស្រុកក្រោយមកគេហៅថា "ក្រុមពញ្ញា" ដោយសារមានចាស់ព្រឹទ្ធាចារ្យមានចំណេះដឹងច្រើន បានចូលរួមនៅក្នុងកិច្ចការផ្សេង ៗ និងក្រុមពញ្ញានេះបង្កើតជំនួយការរបស់មេស្រុកដែលហៅថា "ជំទប់"។ ជំទប់នេះមានអ្នកជំនួយ ការអោយខ្លួនទៀតគេហៅថា "ស្មៀន"។ អ្នកទាំងអស់នេះធ្វើការងារដោយមិនមានប្រាក់ខែទេ ដោយសារសម័យមុនគេគ្មានចាយលុយ(ប្រាក់)ទេ រហូតមកដល់រជ្ជកាលរបស់ព្រះបាទអង្គឌួង ទើបមានប្រាក់សម្រាប់ចាយ ដើម្បីធ្វើការដោះដូរទំនិញ។

ឃុំ សង្កាត់មិនដែលធ្លាប់មានអត្ថិភាពទេនៅក្នុងប្រទេសកម្ពុជា ចាប់តាំងពីមុនការមកដល់នៃពួកអាណានិគមនិយមបារាំងមក។ ដើមកំណើតនៃការគ្រប់គ្រងរដ្ឋបាលរបស់ប្រទេសនេះត្រូវបានរកឃើញក្នុងព្រះរាជក្រឹត្យមួយចុះថ្ងៃទី៥ ខែមិថុនា ឆ្នាំ១៩០៨។ នៅក្នុងព្រះរាជក្រឹត្យនេះបានបង្កើតអោយមានក្របខណ្ឌរដ្ឋបាលសាមញ្ញមួយ តាមរយៈក្របខណ្ឌនេះ ភូមិជាច្រើនបានរួមបញ្ចូលគ្នាបង្កើតជាឃុំមួយ និងបានផ្តល់អោយមានមេឃុំ ដែលកើតចេញតាមរយៈការបោះឆ្នោតពីប្រពលរដ្ឋក្នុងឃុំ ដែលគេហៅថា "មេឃុំ"។ ព្រះរាជក្រឹត្យនេះដដែលគេមិនឃើញមានការផ្តល់ឋានានុក្រមពិសេសណាមួយអោយដល់មេភូមិទេ ទោះបីជាភូមិមានសារៈសំខាន់ចំពោះរចនាសម្ព័ន្ធដែលមាននៅក្នុងឃុំយ៉ាងណាក៏ដោយ។ ក្នុងព្រះរាជក្រឹត្យនេះដែរឃុំមិនត្រូវបានចាត់ទុកថា ជាអង្គភាពរដ្ឋបាលដាច់ដោយឡែកទេ គេស្គាល់តែថ្នាក់ខេត្តស្រុក និងភូមិតែប៉ុណ្ណោះ។

ដើម្បីអោយមានភាពជិតស្និទ្ធរវាងប្រជាជន និងរាជការ ដើម្បីបំពេញការងារអោយបានឆាប់រហ័ស និងមានប្រសិទ្ធភាព រដ្ឋាភិបាលអាណានិគមនិយមបារាំងបានផ្តួចផ្តើមអោយមានព្រះរាជក្រឹត្យពីរទៀតគឺ៖

- ព្រះរាជក្រឹត្យចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩១៩ ដោយអោយរដ្ឋាភិបាលកណ្តាលប្រគល់ធនធានហិរញ្ញវត្ថុរបស់ខ្លួនអោយឃុំជាអ្នកគ្រប់គ្រង និងផ្តល់អំណាចអោយមេឃុំជាអ្នករៀបចំអភិវឌ្ឍន៍មូលដ្ឋានឃុំរបស់ខ្លួនផ្ទាល់។
- ព្រះរាជក្រឹត្យចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩២៥ រដ្ឋាភិបាលអាណានិគមនិយមបារាំងបានផ្តល់អោយមេឃុំ នូវអំណាចក្នុងការរៀបចំចាត់ចែងការងារមួយចំនួនដូចជា ការងារយុត្តាធិការ ការងារ

[26] បណ្ឌិត សាយ បូរី, នីតិរដ្ឋបាលទូទៅ, ២០០២។

គ្រប់គ្រងរដ្ឋបាលឃុំ ការងារហិរញ្ញវត្ថុ ដោយបានកម្រិតអត្រាពន្ធអាករឃុំ កំណត់តម្លៃសម្រាប់ការងាររដ្ឋបាល និងធ្វើបុរេប្រទាន។ ក្រឹត្យនេះត្រូវបានផ្តល់អោយឃុំមានការបោះឆ្នោតរៀបចំក្រុមប្រឹក្សាជាលើកដំបូង ដែលធ្វើអោយរបៀបគ្រប់គ្រងរបស់ឃុំមានលក្ខណ:ខិតជិតប្រជាជន[27]។ ការបោះឆ្នោតនេះ បានជ្រើសរើសមេឃុំម្នាក់ជាអ្នកទទួលខុសត្រូវចំពោះការអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាដែលជានីតិបុគ្គល។ ជំទប់ ត្រូវបានជ្រើសរើសចេញពីក្រុមជំនុំឃុំដើម្បីជួយដល់កិច្ចការមេឃុំ និងទទួលខុសត្រូវក្នុងរង្វង់ដោយឡែកនៃការទទួលខុសត្រូវខាងកិច្ចការរដ្ឋបាល ដែលកិច្ចការរដ្ឋបាលរបស់ឃុំ ជាការទទួលខុសត្រូវទាំងស្រុងដោយលោកមេឃុំសម្រាប់អាណត្តិ៤ឆ្នាំ។

នៅឆ្នាំ១៩៤៣ ដោយសារប្រទេសកម្ពុជាមានសង្គ្រាមឈ្លានពាន ប្រព័ន្ធបោះឆ្នោតនៅឃុំត្រូវបានលប់ចោលស្ទើរតែទាំងស្រុង ដោយដាក់ជំនួសការតែងតាំងមេឃុំ និងជំទប់ ពីអភិបាលខេត្ត ដែលមានការយល់ព្រមពីរ៉េស៊ីដង់របស់បារាំង។ សិទ្ធិស្វ័យសម្រេចរបស់ឃុំត្រូវបានដកហូតដោយរដ្ឋបាលកណ្តាល។

ក្នុងឆ្នាំ១៩៥៥ មានសារាចរណែនាំមួយទៀត អោយរៀបចំការបោះឆ្នោតជ្រើសរើសមេឃុំឡើងវិញ តែការបោះឆ្នោតនេះមិនមានប្រសិទ្ធភាពទេ ព្រោះការបោះឆ្នោតនេះគ្រាន់តែធ្វើឡើងដើម្បីបង្គ្រប់កិច្ចប៉ុណ្ណោះ នេះដោយសារតែប្រជារាស្ត្រមិនមានការចូលរួមយ៉ាងសកម្ម និងមេឃុំមិនមានសមត្ថភាពដឹកនាំប្រជាពលរដ្ឋមានជីវភាពធូរធារជាងមុន។ ដោយសារតែការបរាជ័យនេះហើយទើបមានព្រះរាជក្រមមួយទៀតលេខ ៣៩០នស ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ១៩៥៩ បានតម្រូវអោយមានការបោះឆ្នោតជ្រើសរើសក្រុមជំនុំឃុំ ជានីតិបុគ្គលដូចនៅឆ្នាំ១៩២៥ សម្រាប់រយ:ពេល៤ឆ្នាំ។ តែការបោះឆ្នោតនះមិនដល់រយ:ពេលបីខែផង ព្រះរាជក្រមក៏ត្រូវបានគេដាក់ព្យួរទុកក្នុងរយ:ពេលមិនកំណត់បន្ទាប់ពីបានធ្វើប្រជាមតិនៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៥៩។ រហូតមកដល់ឆ្នាំ១៩៦៩ តាមព្រះរាជក្រមលេខ៣៨៣/៦៩ ចុះថ្ងៃទី១១ ខែកុម្ភ: ឆ្នាំ១៩៦៩ បានប្រកាសកែប្រែអោយឈប់ធ្វើការបោះឆ្នោតជ្រើសរើសក្រុមជំនុំ ចៅសង្កាត់ ជំទប់ ដោយត្រូវតែងតាំងតាមរយ:ដីការខេត្ត តាមសំណើររបស់អភិបាលស្រុក ចាប់ពីពេលនោះមកឃុំ សង្កាត់មិនមានថវិកាផ្ទាល់ខ្លួនទៀតទេ។

នៅខែមិនា ឆ្នាំ១៩៧០ មានការផ្លាស់ប្តូររបបនយោបាយពីរបបរាជានិយម មកជារបបប្រធានាធិបតីនិយម ក្រោមការធ្វើរដ្ឋប្រហារដោយសេនាប្រមុខ លន់ នល់ ទម្លាក់សម្តេចនរោត្តមសីហនុ ពីព្រះប្រមុខរដ្ឋនៃព្រះរាជាណាចក្រកម្ពុជា។ ហើយនៅថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៧២ រដ្ឋធម្មនុញ្ញនៃសាធារណ:រដ្ឋខ្មែរត្រូវបានគេអនុម័ត។ របបថ្មីនេះជាការប៉ុនប៉ងសម្រាប់ការគ្រប់គ្រងបែបវិមជ្ឈការនៅគ្រប់ថ្នាក់រដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ តែដោយសារជាប់រវល់នឹងសង្គ្រាម

[27] សន គីណាល់, កម្មវិធីសិលា(វិមជ្ឈការនៅកម្ពុជា), ២០០២។

ទាំងក្នុងស្រុក និងក្រៅស្រុកផង ការបោះឆ្នោតគ្រប់ថ្នាក់មូលដ្ឋានមិនអាចដំណើរការបាននោះទេ។ មេឃុំនៅតែត្រូវបានតែងតាំងដោយអភិបាលខេត្តដដែល រហូតមានបដិវត្តមួយទៀតបានកើតឡើងផ្តួលរលំរបបសាធារណៈរដ្ឋខ្មែរនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥បង្កើតជារបបមួយថ្មីដែលមានឈ្មោះថា "កម្ពុជាប្រជាធិបតេយ្យ"។ តាមរដ្ឋធម្មនុញ្ញដែលបានអនុម័តនៅថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៦ នៅក្នុងរបបនេះគ្មានបានកំណត់ច្បាស់លាស់ពីរចនាសម្ព័ន្ធតួនាទីដែនដីរដ្ឋបាលឡើង ទោះបីនៅក្នុងរដ្ឋធម្មនុញ្ញបានចែងអោយមានជាថ្នាក់មជ្ឈិម ភូមិភាគថ្នាក់តំបន់ និងសហករភូមិឃុំយ៉ាងណាក៏ដោយ។

បន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យដួលរលំ រដ្ឋធម្មនុញ្ញថ្មីមួយទៀតបានអនុម័តថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ១៩៨១ បានបង្កើតឡើងនូវរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា។ តាមរដ្ឋធម្មនុញ្ញនេះបានកំណត់ដែនដីរដ្ឋបាលដោយចែកជាខេត្តក្រុង ស្រុក ខណ្ឌ ទីរួមខេត្ត ឃុំ សង្កាត់ ហើយគ្រប់ដែនដីរដ្ឋបាលដែលមានខាងលើមានឈ្មោះថា "គណៈកម្មាធិការប្រជាជនបដិវត្តន៍" ដែល គេប្រើប្រាស់តាមសម័យកាលមួយដែលប្រទេសជាតិស្ថិតក្នុងស្ថានភាពទើបរំដោះពីរបបប្រល័យពូជសាសន៍។ គណៈកម្មាធិការប្រជាជនបដិវត្តន៍ ត្រូវបានជ្រើសតាំងឡើងតាមការបោះឆ្នោតជាសកល ដោយស្មើភាពដោយចំពោះ និងតាមវិធីជ្រើសរើសសន្លឹកឆ្នោតជាសម្ងាត់។

នៅថ្ងៃទី១៣ ខែមេសា ឆ្នាំ១៩៨៩ របបសាធារណៈរដ្ឋប្រជាមានិតកម្ពុជាត្រូវបានប្តូរឈ្មោះរបស់ខ្លួនមកជារបបរដ្ឋកម្ពុជាវិញ ដោយដែនរដ្ឋបាលគ្រប់គ្រងត្រូវបានប្តូរឈ្មោះមកជា"គណៈកម្មាធិការប្រជាជន"។

នៅឆ្នាំ១៩៩៣ មានការរៀបចំការបោះឆ្នោតជាតិ ដោយបានផ្លាស់ប្តូររបបពីរដ្ឋកម្ពុជាមកជារបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញវិញ។ ការវិវត្តនេះផងដែរបានធ្វើអោយមានការផ្លាស់ប្តូរប្រព័ន្ធនៃការគ្រប់គ្រងឃុំ សង្កាត់ ពីប្រធានគណៈកម្មាធិការប្រជាជន ទៅជាមេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង ជំនួសវិញ។

តាមមាត្រា១២៦នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ចាស់ និងវិសោធនកម្ម ឆ្នាំ១៩៩៩ មាត្រា១៤៥ថ្មីបានចែងថាទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ចែកចេញជាខេត្តនិងក្រុង។ ខេត្តចែកចេញជាស្រុក ស្រុកចែកចេញជាឃុំ ក្រុងចែកចេញជាខណ្ឌ ខណ្ឌចែកចេញជាសង្កាត់។ ផ្តើមពីឆ្នាំ១៩៩៦-១៩៩៧ ក្នុងនីតិកាលទី១នៃរដ្ឋសភា ក្រសួងមហាផ្ទៃបានសិក្សាស្រាវជ្រាវរៀបចំពង្រៀងច្បាប់ និងលិខិតបទដ្ឋានគ្រប់គ្រងឃុំ សង្កាត់អោយក្លាយទៅជានីតិបុគ្គល។ សេចក្តីព្រាងច្បាប់នេះ(ការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់) និងសេចក្តីព្រាងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបានរៀបចំរួចរាល់ ប៉ុន្តែដោយសារពេលវេលា និងស្ថានភាពនយោបាយកម្ពុជាតម្រូវអោយមានការគិតគូរជាចម្បង ចំពោះការរៀបចំការបោះឆ្នោតជាសកល ដើម្បីធ្វើការជ្រើសរើសតំណាងរាស្ត្រអាណត្តិទី២នៃ

រដ្ឋសភា បាននាំអោយមានការផ្អាកបណ្តោះអាសន្ននូវការពិភាក្សានៅទីស្តីការគណៈរដ្ឋមន្ត្រី។ បន្ទាប់ពីបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រនីតិកាលទី២រួច ក្រសួងមហាផ្ទៃ នៅតែបន្តលើកយកសេចក្តីព្រាងច្បាប់ទាំងពីរមកធ្វើការពិភាក្សាសារជាថ្មីទៀត។[28] រហូតមកដល់ថ្ងៃទី១៨ ខែមករា ឆ្នាំ២០០១ រដ្ឋសភាបានអនុម័តច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ហើយនៅថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០០១ រដ្ឋសភាបានធ្វើការអនុម័តច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ដែលនិន្នាការថ្មីក្នុងការកែទម្រង់រដ្ឋបាលរបស់ក្រសួងមហាផ្ទៃបានធ្វើអោយមានការរៀបចំ ការគ្រប់គ្រងឃុំ សង្កាត់ តាមរយៈការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់កើតជារូបរាង។ នៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០០២ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ លើកទី១បានធ្វើឡើង។ ដោយសារភាពជោគជ័យនេះហើយទើបនៅថ្ងៃទី១ ខែមេសា ឆ្នាំ២០០៧ មានការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់លើកទី២ត្រូវបានធ្វើឡើង និងអនុវត្តនយោបាយគ្រប់គ្រងបែបវិមជ្ឈការនៅថ្នាក់ឃុំ សង្កាត់ ព្រោះប្រព័ន្ធគ្រប់គ្រងតាមបែបវិមជ្ឈការ ជាប្រព័ន្ធមួយដែលរដ្ឋាភិបាលកណ្តាលផ្ទេរអំណាច ការទទួលខុសត្រូវលើកិច្ចការមួយចំនួនអោយមូលដ្ឋានជាអ្នកចាត់ចែង និងបម្រើប្រយោជន៍ដល់ថ្នាក់មូលដ្ឋាននោះដែលស្ថិតនៅក្រោមការដឹកនាំដោយតំណាងឃុំ សង្កាត់ ដែលជាប់ឆ្នោត ដើម្បីអនុវត្តដែនសមត្ថកិច្ចតាមបែបវិមជ្ឈការនៅក្នុងឃុំ សង្កាត់។

បដិវត្តន៍ថ្មីមួយនៅក្នុងក្របខ័ណ្ឌរដ្ឋបាលនៃប្រទេសកម្ពុជា មានជំហានដ៏សំខាន់មួយគឺការប្រកាសអោយប្រើប្រាស់ច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខ័ណ្ឌ នៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលបានអនុម័តដោយរដ្ឋសភាកាលពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៨។ ការកើតឡើងនូវបដិវត្តន៍ថ្មីនេះហើយ ដែលធ្វើអោយប្រទេសកម្ពុជាមានការបែងចែកថ្នាក់រដ្ឋបាលកាន់តែច្រើន និងមានសភាពកាន់តែស្មុគស្មាញ។ ព្រះរាជាណាចក្រកម្ពុជាត្រូវបែងចែកជា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អោយក្លាយទៅជានីតិបុគ្គលនៃនីតិសាធារណៈ។ នីតិបុគ្គលនីមួយៗ ត្រូវតែមានក្រុមប្រឹក្សាជាតំណាងដែលត្រូវបោះឆ្នោតដោយអសកល ដោយសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់។ ក្រុមប្រឹក្សានេះមានអាណត្តិ៥ឆ្នាំ(ប្រាំឆ្នាំ) ហើយត្រូវផុតកំណត់ពេលដែលក្រុមប្រឹក្សាថ្មីចូលកាន់តំណែង។ សម្រាប់ក្រុមប្រឹក្សារាជធានីមានសមាជិកមិនលើសពី២១រូប ក្រុមប្រឹក្សាខេត្តមានសមាជិកពី៩រូបដល់២១រូប តាមភាពចាំបាច់នៃខេត្តនីមួយៗ រីឯក្រុមប្រឹក្សាក្រុងមានចំនួនសមាជិកពី៧រូបដល់១៥រូប ហើយក្រុមប្រឹក្សាស្រុកនិងខណ្ឌមានសមាជិកពី៧រូបដល់១៩រូប[29]។

[28] កៅមុយថង, វិមជ្ឈការនិងវិសហមជ្ឈការ, ២០០៧។

[29] ច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, ២០០៨។

## VII- បញ្ហាប្រឈមមុខចំពោះវិមជ្ឈការនៅកម្ពុជា

ទោះជានយោបាយវិមជ្ឈការនៅប្រទេសកម្ពុជា បានចាក់ឫសចូលក្នុងប្រព័ន្ធគ្រប់គ្រង មួយទស្សវត្សយ៉ាងណាក្ដី ក៏ប្រទេសនេះនៅតែមានការព្រួយបារម្ភ និងការខ្វះចន្លោះជាច្រើនរបស់រាជរដ្ឋាភិបាល និងថ្នាក់រដ្ឋបាលមូលដ្ឋានដែលមានក្រុមប្រឹក្សាឃុំ សង្កាត់ចំនួន១៦២១រូប នៅទូទាំងប្រទេស។ បញ្ហាប្រឈមមុខរបស់កម្ពុជាទាក់ទងនឹងវិមជ្ឈការនេះរួមមាន ប្រព័ន្ធនៃការទទួលខុសត្រូវ និងតម្លាភាព ការចូលរួម និងសង្គមស៊ីវិល ការរៀបចំចាត់ចែងសារពើពន្ធ និងសមត្ថភាព។

### ១- ប្រព័ន្ធនៃការទទួលខុសត្រូវ និង តម្លាភាព

ជាការកត់សម្គាល់ និងការព្រួយបារម្ភមួយ ដែលទាក់ទងនឹងទំនួលខុសត្រូវរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ជាបរិបទជាតិដែលក្រុមប្រឹក្សាទាំងនេះត្រូវបានអនុវត្ត។ នៅខណៈពេលដែលប្រព័ន្ធវិមជ្ឈការថ្មីមួយនៃអភិបាលកិច្ច អាចនឹងអនុម័តយកវិធានការផ្សេងៗ ដើម្បីធានា ឬជម្រុញទំនួលខុសត្រូវរបស់អង្គភាពរដ្ឋបាលមូលដ្ឋាន។ គេគួរតែដឹងថាអង្គភាពរដ្ឋបាលមូលដ្ឋានទាំងនេះនឹងដំណើរការទៅក្នុងបរិបទជាតិ(គោលនយោបាយជាតិ) ដែលទំនួលខុសត្រូវមានកម្រិតខ្សោយ ហើយដែលគ្មានទម្លាប់ដាក់ទណ្ឌកម្ម(ទទួលទោស) អោយបានត្រឹមត្រូវដល់មន្ត្រីដែលបានបរាជ័យមិនបានបំពេញមុខងាររបស់ខ្លួន។ ម្យ៉ាងទៀត តម្លាភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ទាក់ទងទៅនឹងទីតាំងរបស់ក្រុមប្រឹក្សាមានន័យថា តម្លាភាពរបស់ក្រុមប្រឹក្សាឃុំសង្កាត់មួយ នឹងត្រូវបានកាត់បន្ថយយ៉ាងច្រើន ប្រសិនបើការិយាល័យឃុំ(សាលាឃុំ) ក៏ជាទីសំណាក់អាស្រ័យរបស់ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់(មេឃុំ ចៅសង្កាត់)នោះ។

សាលាឃុំប្រសើរបំផុតគួរតែជាអគារសាធារណៈមួយដែលអាចផ្ដល់សិទ្ធិចេញចូលដល់ប្រជាពលរដ្ឋបោះឆ្នោត និងទំនាក់ទំនងការងារក្នុងដែនឃុំសង្កាត់របស់ខ្លួន។ នៅពេលដែលសាលាឃុំសង្កាត់ជាផ្ទះរបស់ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់នោះភាពខុសគ្នារវាងសាធារណៈ និងឯកជនភាពមានភាពស្រពិចស្រពិលខ្លាំង។ ការបារម្ភជាចុងក្រោយនោះ គឺសំដៅថាច្បាប់គ្រប់គ្រងរដ្ឋបាលឃុំសង្កាត់ មិនបានបង្កើតអោយមានឯកជនមានទំនាក់ទំនងខ្លាំងក្លាណាមួយរវាងថ្នាក់ឃុំ សង្កាត់ និងភូមិ(អ្នកភូមិ) នៅក្នុងរង្វង់ឃុំនោះទេ។

ខណៈដែលបទបញ្ញាតិដែលបានពិព័ណ៌នាខាងលើតម្រូវអោយមានការជ្រើសតាំងមេភូមិនោះ។ ច្បាប់នេះទៀតសោធមិនបានផ្ដល់មាគ៌ាណាមួយទេ ដើម្បីជ្រើសរើសមេភូមិ ដែលប្រជាពលរដ្ឋមានសិទ្ធិទទួលបានសិទ្ធិតំណាងនៅថ្នាក់ភូមិរបស់ខ្លួននោះ(មេភូមិ)។

## ២- ការចូលរួម និងសង្គមស៊ីវិល

ការធ្វើអន្តរកម្មសកម្មភាព រវាងរដ្ឋាភិបាល និងអង្គការចាត់តាំងសង្គមស៊ីវិលនានាដែលបានបកស្រាយពីវិមជ្ឈការបានអះអាងជាមូលដ្ឋានថា ការចូលរួមកាន់តែច្រើនក្នុងដំណើរការនៃការអនុវត្តអភិបាលកិច្ចរបស់ប្រជាពលរដ្ឋ គឺមានឥទ្ធិពលខ្លាំងជាមួយផ្នែកចិត្តវិទ្យា។ បញ្ហានេះបានជួបប្រទះច្រើននៅក្នុងបរិបទនៃប្រទេសកម្ពុជា ដែលការចូលរួមនានាត្រូវបានបំបាក់ទឹកចិត្តជាប្រពៃណីដល់ប្រជាពលរដ្ឋក្នុងសង្គម និងទទួលយកដោយគ្មានការតវ៉ា នូវការសម្រេចចិត្តនានារបស់អ្នកដឹកនាំរបស់ខ្លួន។ ជាទូទៅស្ថាប័នរដ្ឋាភិបាលមិនសូវមានការឆ្លើយតបនូវសេចក្តីត្រូវការដ៏ប្រសើរចំពោះមុខនោះទេ លុះត្រាតែមានសំពាធពីថ្នាក់ក្រោម។ សម្រាប់កម្ពុជាដែលពុំធ្លាប់ទម្លាប់មានសង្គមស៊ីវិលជួយដាក់សំពាធលើរដ្ឋាភិបាល អោយមានការឆ្លើយតបកាន់តែប្រសើរនោះ ការកើតមាននូវតួនាទីស្របច្បាប់ដ៏សំខាន់មួយសម្រាប់ NGOs ក្នុងការចូលរួមសម្របសម្រួលរាល់សកម្មភាពផ្សេងៗរបស់ប្រជាពលរដ្ឋមូលដ្ឋាន និងអាជ្ញាធរ ដែលអាចជម្រុញអោយការឆ្លើយតបនានាកាន់តែមានប្រសិទ្ធភាពឡើង។

## ៣- ការរៀបចំចាត់ចែងសារពើពន្ធ

ការផ្តល់អំណាចមកថ្នាក់មូលដ្ឋាន មិនត្រូវបានធានាថា អំណាចដែលបានផ្តល់អោយក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការកំណត់យកពន្ធផ្សេងៗ នៅមូលដ្ឋានមានប្រសិទ្ធភាពនោះទេ។ សំពាធរវាងឃុំ សង្កាត់អ្នកមាន និងឃុំ សង្កាត់ក្រីក្រ (ឃុំនៅជនបទ និងសង្កាត់នៅទីក្រុងដែលសម្បូរភោគទ្រព្យ) ដែលនេះជាការធានាធ្វើយ៉ាងណាអោយឃុំ សង្កាត់មានតុល្យភាពរបស់ខ្លួនក្នុងការដោះស្រាយរាល់បញ្ហាប្រមូលសារពើពន្ធនេះ។ កត្តានេះអាចធ្វើអោយរដ្ឋបាលឃុំ សង្កាត់កាន់តែមានការប្រយ័ត្នប្រយែងខ្ពស់ ចំពោះបញ្ហានានាដូចជា ការប្រមូលពន្ធ វិធានការសមភាពដែលត្រូវយកមកអនុវត្ត និងការរៀបចំសារពើពន្ធ ចំពោះប្រជាពលរដ្ឋដែលរស់នៅក្នុងស្ថានភាពក្រីក្រ។

ចំណូលផ្ទាល់ខ្លួនរបស់ឃុំ សង្កាត់ (មូលនិធិដែលក្រុមប្រឹក្សាឃុំ សង្កាត់ប្រមូលបានក្នុងមូលដ្ឋានរបស់ខ្លួន) ជាប្រភពផ្តល់មូលនិធិយ៉ាងសំខាន់សម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់ថ្មី។ លទ្ធផលដែលទទួលបាន ទីមួយ គឺក្រុមប្រឹក្សាដែលមានថវិកាតិច ឬគ្មានសោះនឹងបាត់បង់ការគាំទ្រពីនិវេសន៍ជនបទមូលដ្ឋានរបស់ពួកគេ។ ទីពីរ អង្គការចាត់តាំងផ្សេងៗដូចជា NGOs សមាគមដែលមានមូលនិធិច្រើនជាង អាចត្រូវបានចាត់ទុកអង្គការអភិវឌ្ឍន៍មូលដ្ឋាន(CBOs)សំខាន់ច្រើនជាងក្រុមប្រឹក្សាដែលបានជាប់ឆ្នោតថ្មី។ ទីបី ឃុំសង្កាត់ដែលមាន មូលដ្ឋានប្រមូលសារពើពន្ធ ក្នុងមណ្ឌលបោះឆ្នោតរបស់ពួកគេប្រសើរជាងឃុំ សង្កាត់ដទៃទៀត ចន្លោះគម្លាតរវាងឃុំសង្កាត់មានទ្រព្យ និង

ឃុំ សង្កាត់គ្មានទ្រព្យកាន់តែមានគម្លាតឆ្ងាយពីគ្នា។ ប្រសិនបើគ្មានរូបមន្តដ៏ស័ក្តិសិទ្ធិមួយ សម្រាប់ការផ្ទេរសារពើពន្ធពីរដ្ឋបាលកណ្តាល ដែលមានវិធានការសមភាពច្បាស់លាស់ ការរៀបចំផ្តល់មូលនិធិនឹងរើសអើងដោយចៀសមិនរួច ចំពោះឃុំ សង្កាត់ដែលមានទំហំតូច(ក្រីក្រ) ឬឃុំ សង្កាត់ដែលនៅឆ្ងាយដាច់ស្រយាល ដែលមិនមានសមត្ថភាពគ្រប់គ្រាន់ប្រមូលពន្ធដូចឃុំ សង្កាត់ធំ(មានទ្រព្យសម្បត្តិច្រើន)។

## ៤- ប្រភពចំណូលរបស់ឃុំ សង្កាត់

### ៤.១- ចំណូលមូលនិធិឃុំ សង្កាត់

- ចំណូលមូលនិធិឃុំ សង្កាត់មានការរួមចំណែកពីចំណូលចរន្តពីថវិការដ្ឋ ការចូលរួមពីជំនួយឥតសំណង និងការខ្ចីបានពីម្ចាស់ជំនួយ និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិនានាជាដើម ហើយការចំណាយរបស់មូលនិធិឃុំ សង្កាត់គឺបានពីការផ្ទេរប្រចាំឆ្នាំទៅក្នុងថវិកាឃុំ សង្កាត់។

- សមាសភាគរបស់មូលនិធិឃុំ សង្កាត់ គឺធនធានសរុបនៃមូលនិធិដែលចែកចេញជាពីរសមាសភាគដូចតទៅៈ សមាសភាគរដ្ឋបាលទូទៅដែលមានចំនួនច្រើនជាងមួយភាគបី(១/៣) ធនធាននៃសមាសភាគនេះ គឺជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីបំពេញមុខងាររដ្ឋបាលទូទៅលើការចំណាយប្រតិបត្តិការ និងវិនិយោគដោយរដ្ឋបាលឃុំ សង្កាត់ក្នុងការអនុវត្តភារកិច្ចរដ្ឋបាលរបស់ខ្លួនដូចជាប្រាក់បំណាច់របស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ បៀវត្សសម្រាប់មន្ត្រីឃុំ សង្កាត់ ការជួល ឬការទិញទីតាំង និងសម្រាប់ការចំណាយទៅលើសម្ភារៈ និងចំណាយផ្សេងៗទៀតរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។ ធនធានសមាសភាគនេះ ជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការបំពេញបានការទទួលខុសត្រូវ សម្រាប់លើកស្ទួយសេដ្ឋកិច្ចមូលដ្ឋាន កិច្ចអភិវឌ្ឍន៍សង្គម និង សុខមាលភាពទូទៅរបស់ប្រជាពលរដ្ឋនៅមូលដ្ឋានដូចជា ការសង្កេត គំនូសប្លង់ ការកសាង ការជួសជុល ការថែទាំផ្លូវ ផ្សាលូទឹក មណ្ឌលសុខភាព សាលារៀន សហគមន៍ សំណង់ធារាសាស្ត្រ ឃ្លាំងផ្ទុកកសិផល ប្រព័ន្ធផ្គត់ផ្គង់ទឹក និងហេដ្ឋារចនាសម្ព័ន្ធ សេដ្ឋកិច្ច សង្គមផ្សេងទៀត ការចំណាយលើមន្ត្រី/ បុគ្គលិក និងចំណាយចរន្តដែលពាក់ព័ន្ធប្រតិបត្តិការហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន និងការផ្តល់សេវាចំណាយគាំទ្រលើកម្មវិធីអភិវឌ្ឍន៍សហគមន៍ ដែលចាត់ចែងដោយអង្គការមិនមែនរដ្ឋាភិបាលនៅមូលដ្ឋាន និងអង្គការជួយសហគមន៍ រួមទាំងយុទ្ធនាការផ្តល់ព័ត៌មាន និងអប់រំសម្រាប់ស្ត្រី និងយុវវ័យនៅមូលដ្ឋាន ការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ និងកម្មវិធីដទៃទៀតដែលមានឥទ្ធិពលដល់សុខភាពសង្គម និងប្រជាពលរដ្ឋក្នុងមូលដ្ឋាន[30]។

[30] សន គីណាល់,កម្មវិធីសិលា(វិមជ្ឈការនៅកម្ពុជា), ២០០២។

### ៤.២- ចំណូលផ្ទាល់ឃុំ សង្កាត់

ឃុំ សង្កាត់មានថវិកាផ្ទាល់ដែលបានមកពីប្រភពចំណូលផ្សេងៗនៅក្នុងឃុំ សង្កាត់ផ្ទាល់ ដូចជា កម្រៃសេវាផ្សេងៗលើដីធ្លី ឬអាគារសារពើពន្ធមូលដ្ឋានដែលបានទទួលពីការអនុវត្តតួនាទីរបស់ខ្លួន ក្នុងនាមអាជ្ញាធរដែនដីលើកម្រៃសេវាលើលិខិតរដ្ឋបាលផ្សេងៗ នៅក្នុងដែនដីរបស់ខ្លួន និងទម្រង់បែបបទផ្សេងៗ ទៀតដែលពាក់ព័ន្ធជាមួយប្រជាពលរដ្ឋ និងអាជ្ញាធរឃុំ សង្កាត់។

### ៤.៣- ចំណូលមុខងារជាភ្នាក់ងារ

ឃុំ សង្កាត់មានសិទ្ធិទទួលចំណូលដែលបានមកពីការបំពេញភារកិច្ចដោយឃុំ សង្កាត់ ជំនួសស្ថាប័នកណ្តាលរដ្ឋបាលខេត្ត ក្រុង និងស្ថាប័នដទៃទៀតដែលហៅថា ចំណូលមុខងារជាភ្នាក់ងារ។ និយាយជារួម គឺការបំពេញភារកិច្ចក្នុងនាមរាជរដ្ឋាភិបាលជាតិ ដែលមានឈ្មោះថា "មុខងារជាភ្នាក់ងារ"។

# VIII- សេចក្តីសន្និដ្ឋាន និង អនុសាសន៍

## ១- សេចក្តីសន្និដ្ឋាន

យោងតាមការសិក្សាស្រាវជ្រាវ ពីដំណើរការនយោបាយវិមជ្ឈការរបស់ប្រទេសកម្ពុជា រួចមកយើងឃើញថាមានដំណើរការល្អបង្គួរ ព្រោះសកម្មភាព/សេវាដែលឃុំ ឬអង្គការ ស្ថាប័ននានាទាំងអស់បានឆ្លុះបញ្ចាំងពីដំណើរការអភិវឌ្ឍន៍ស្ទើគ្រប់ផ្នែក(វិស័យ)ទាំងអស់របស់ថ្នាក់មូលដ្ឋាន ដោយបានធ្វើអោយកាន់តែប្រសើរឡើងនូវវឌ្ឍនៈភាព និងភាពរីកចម្រើនទៅថ្ងៃអនាគតរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន។ ដោយសារតែនយោបាយវិមជ្ឈការ ជារឿងថ្មីសម្រាប់ថ្នាក់មូលដ្ឋានមែនតែសកម្មភាពរបស់ថ្នាក់មូលដ្ឋានបានធ្វើអោយប្រជាពលរដ្ឋ និង សហគមន៍ទាំងមូលមានភាពប្រសើរឡើង តាមរយៈការអនុវត្តកិច្ចការនៅថ្នាក់មូលដ្ឋាន និង ជាភ្នាក់ងារតំណាងរដ្ឋ ដែលសកម្មភាពទាំងនេះផ្តោតសំខាន់ទៅលើផ្នែកចំនួនប្រាំ គឺផ្នែកសេដ្ឋកិច្ច ផ្នែកសង្គមកិច្ច ផ្នែកធនធានធម្មជាតិ និងបរិស្ថានផ្នែករដ្ឋបាល និងសន្តិសុខ និងផ្នែកយេនឌ័រ។

នយោបាយវិមជ្ឈការពិតជា ប្រព័ន្ធគ្រប់គ្រងដ៏ល្អប្រសើរបំផុតសម្រាប់ប្រទេសកម្ពុជា ជាពិសេសសម្រាប់ប្រជាពលរដ្ឋតាមមូលដ្ឋានតែម្តង ដោយហេតុថា ប្រព័ន្ធដឹកនាំតាមបែបវិមជ្ឈការគឺមានគោលដៅជាចម្បងឆ្ពោះទៅរកការធ្វើអោយមានការទទួលខុសត្រូវ នៅកម្រិតថ្នាក់ក្រោមជាតិអោយកាន់តែច្រើន និងមានភាពជិតស្និទ្ធ ជាមួយប្រជាពលរដ្ឋនៅក្នុងដែនដីមូលដ្ឋាន ម្យ៉ាងទៀតអ្វីដែលសំខាន់ទៅទៀតនោះ គឺការធ្វើអោយមានការចូលរួមពីគ្រប់មជ្ឈដ្ឋានដូចជា អាជ្ញាធរដែនដី អង្គ

ការ ស្ថាប័ន និងវិស័យឯកជននានា ជាពិសេសគឺការចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងសហគមន៍មូលដ្ឋានផងដែរ ពីព្រោះថានយោបាយវិមជ្ឈការនឹងធ្វើអោយក្រុមប្រឹក្សាឃុំមានលទ្ធភាពកាន់តែខ្លាំង ក្នុងការឆ្លើយតបសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋក្នុងឃុំកាន់តែប្រសើរ។

ក្រុមប្រឹក្សាឃុំបានបំពេញការងារបានយ៉ាងច្រើន នៅក្នុងមូលដ្ឋានរបស់ខ្លួនបើទោះបីការធ្វើសកម្មភាពមិនបានពេញលេញ ដើម្បីបម្រើសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋក៏ដោយ។ បើយោងទៅលើការស្រាវជ្រាវបានបង្ហាញថា ការផ្តល់លទ្ធភាពដល់ក្រុមប្រឹក្សាឃុំ ដើម្បីបំពេញមុខងារផ្ទាល់ និងភ្នាក់ងារតំណាងរដ្ឋ។ ការបំពេញមុខងារនេះ នៅមានកម្រិតនៅឡើយ ដោយមើលឃើញយ៉ាងជាក់ស្តែងពី ការកង្វះធនធានមនុស្ស ធនធានថវិកា ធនធានសម្ភារៈ និងធនធានបច្ចេកទេស រីឯសេវាដែលឃុំបានផ្តល់អោយប្រជាពលរដ្ឋក្នុងឃុំ ជាសេវាកម្មដែលភាគច្រើនជាកិច្ចការសម្របសម្រួល និងលិខិតស្នាមជាដើម។

ទន្ទឹមនឹងភាពរីកចម្រើន និងចំណុចល្អខាងលើនេះ ឃុំ/ ក្រុមប្រឹក្សាឃុំ ក៏មានចំណុចអវិជ្ជមានដែលជៀសមិនផុតដូចជា ប្រជាពលរដ្ឋមិនសូវមានការយល់ដឹងពីតួនាទី ការផ្តល់សេវាកម្មនានា និងភាពជាម្ចាស់ដែនដីមូលដ្ឋាន ក្នុងការធ្វើអោយឃុំមានការរីកចម្រើន និងកម្រិតជីវភាពរបស់ប្រជាពលរដ្ឋបានល្អប្រសើរនោះទេ។ តាមលទ្ធផលស្រាវជ្រាវបានបង្ហាញថាប្រជាពលរដ្ឋនៅតែមិនយល់ពីភាពចាំបាច់របស់ពួកគាត់ ក្នុងការចូលរួមរាល់សកម្មភាពអភិវឌ្ឍន៍នានារបស់ឃុំដូចជាការរៀបចំផែនការប្រចាំឆ្នាំ ការប្រជុំនានា និងសកម្មភាពផ្សេងទៀតក្នុងឃុំរបស់ខ្លួន។ការដែលប្រជាពលរដ្ឋមិនបានចូលរួមច្រើនរាល់សកម្មភាពរបស់ឃុំនោះ នឹងធ្វើអោយដំណើរការការងារអភិវឌ្ឍន៍ជួបនូវបញ្ហា ឬឧបសគ្គធ្ងន់ធ្ងរ គឺការយល់មិនពេញចិត្តនឹងសេវាកម្មដែលមិនបានឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ពួកគាត់។

ឯកសារគតិយុត្តិ ច្បាប់មួយចំនួនដែលចេញដោយស្ថាប័នព្រះមហាក្សត្រ រាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃ និងអន្តរក្រសួងនានា បានបង្ហាញអោយឃើញថា ភាពសម្បូរបែបជាច្រើនក្នុងការអោយឃុំ ជានីតិបុគ្គលក្នុងស្មារតីបម្រើដល់ដែនដីមូលដ្ឋាន ប៉ុន្តែឯកសារទាំងនោះគឺចេញដោយមិនមានលក្ខណៈជាប្រព័ន្ធ និងពិបាកយល់សម្រាប់ឃុំដែលចំណេះដឹងរបស់ឃុំនៅមានកម្រិតនៅឡើយនោះ។

សរុបសេចក្តីមក យើងឃើញអាចធ្វើការសន្និដ្ឋានបានថា ថ្វីត្បិតមានសកម្មភាពអសកម្មមួយចំនួនយ៉ាងណាក៏ដោយ ក៏ឃុំនៅតែសម្រេចបាននូវប្រសិទ្ធភាព និងប្រសិទ្ធផលខ្លះដែរដូចជា សេវាផ្នែករដ្ឋបាល និងសន្តិសុខ សការផ្សព្វផ្សាយពីច្បាប់ ទាក់ទងនឹងបរិស្ថាន យេនឌ័រ និងកិច្ចការសម្របសម្រួលកិច្ចការរបស់ប្រជាពលរដ្ឋ(អត្រានុកូលដ្ឋាន) កិច្ចការសម្របសម្រួលដល់អង្គការ ឬ

ស្ថានប័នដែលជាដៃគូអភិវឌ្ឍន៍នានារបស់ឃុំជាដើម។ កិច្ចការទាំងនេះបានធ្វើអោយប្រសើរឡើង ការឆ្លើយតបបានមួយចំនួនទៅដល់ភូមិទាំង១៧នៃឃុំបុស្សូរ។ ដូច្នេះ ប្រព័ន្ធគ្រប់គ្រងតាម នយោបាយវិមជ្ឈការ នឹងធ្វើអោយប្រជាពលរដ្ឋនៅក្នុងឃុំទាំងមូល មានកម្រិតជីវភាពបានល្អប្រសើរ ឡើង នូវទៅតាមដំណាក់កាលនៃភាពកាន់តែរឹងមាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ(ថ្នាក់មូលដ្ឋាន) និង ប្រជាពលរដ្ឋកាន់តែមានការយល់ពីតម្លៃនៃ ការចូលរួមសកម្មភាពនានាក្នុងការអភិវឌ្ឍន៍នៅ មូល ដ្ឋាន។ ជាងនេះទៅទៀតសម្រាប់ប្រទេសកម្ពុជាទាំងមូលនឹងកាន់តែមានវឌ្ឍនៈភាព និងរីកចម្រើន លើគ្រប់វិស័យ។

## ២- អនុសាសន៍

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវ អំពីដំណើរការនយោបាយវិមជ្ឈការនៃការអភិវឌ្ឍន៍ របស់ប្រទេសកម្ពុជា មកយើងឃើញថា នៅថ្នាក់មូលដ្ឋាននូវមានចំណុចខ្វះខាតមួយចំនួនដែលគួរតែ ធ្វើការកែលម្អដូចតទៅ៖

- គ្រប់បណ្តាអន្តរក្រសួង ឬស្ថាប័នដែលមានការពាក់ព័ន្ធ គួរមានការយកចិត្តទុកដាក់ខ្ពស់ទៅ លើការពង្រឹង និងការបណ្តុះបណ្តាលធនធានមនុស្ស(ក្រុមប្រឹក្សាឃុំ) បង្កើនការងារបច្ចេកទេស និង ផ្តល់សម្ភារៈអោយបានគ្រប់គ្រាន់ ដើម្បីធានា និងជម្រុញការងារ(សេវាកម្ម) របស់ក្រុមប្រឹក្សាឃុំអោ យមានប្រសិទ្ធភាពខ្ពស់។
- កិច្ចការរបស់ក្រុមប្រឹក្សាឃុំ គឺមានទំហំធំសម្រាប់ដែនដីគ្រប់គ្រងរបស់ខ្លួន ដូច្នេះថវិកាជាតិ ប្រចាំឆ្នាំគួរផ្តល់អោយបានគ្រប់គ្រាន់ក្នុងការបំពេញការងារ ជាភ្នាក់ងារបម្រើកិច្ចការថ្នាក់មូលដ្ឋាន និងជាភ្នាក់ងារតំណាងរដ្ឋ និងគួរមានការលើកទឹកចិត្តដល់ក្រុមប្រឹក្សាឃុំលើសម្ភារៈ ស្មារតី និងជា ពិសេសថវិកា ដើម្បីអោយក្រុមប្រឹក្សាមានឆន្ទៈខ្ពស់បម្រើការងារអោយកាន់តែប្រសើរ ដល់ផល ប្រយោជន៍ប្រជាពលរដ្ឋ និងសង្គមជាតិទាំងមូល។
- ការផ្ទេរសិទ្ធិ អំណាច ការគ្រប់គ្រង និងធនធានមួយចំនួនពីរដ្ឋបាលថ្នាក់ជាតិ(រដ្ឋបាលថ្នាក់ កណ្តាល)មិនបានពេញលេញ ដែលធ្វើអោយការបំពេញការងាររបស់ឃុំនៅមានកម្រិត។ ដូច្នេះរាជ រដ្ឋាភិបាល និងអន្តរក្រសួង គួរទំលាក់នូវប្រតិភូកម្មមុខងារអោយបានច្រើនទៅតាមទំហំការងារ និង ដែនដីវិសាលភាពរដ្ឋបាលរបស់ឃុំ។
- ក្នុងដំណើរការនៃការអភិវឌ្ឍន៍របស់ឃុំ គ្រប់ក្រសួង ឬស្ថាប័នដែលមានការពាក់ព័ន្ធ គួរអោយ មានស្ត្រីចូលរួមអោយបានច្រើនគ្រប់វិស័យ(ផ្នែក)ទាំងប្រាំ ជាពិសេសផ្នែកសេដ្ឋកិច្ច និងការថែរក្សា សណ្តាប់ធ្នាប់ តាមរយៈការកសាងសមត្ថភាព និងលើកទឹកចិត្តស្ត្រីអោយបានចូលរួមគ្រប់សកម្មភាព របស់ឃុំ។

- រាល់ការសិក្សាវិស័យអាទិភាព និងកិច្ចអភិវឌ្ឍន៍នានា គួរតែមានការចូលរួមយ៉ាងពេញលេញពីប្រជាពលរដ្ឋ ដើម្បីបង្ហាញសេចក្តីត្រូវការ គំនិតយោបល់ ធនធានថវិកា ស្មារតី និងធនធានសម្ភារៈមួយចំនួន ដើម្បីរួបរួមកម្លាំងជាធ្លុងមួយក្នុងការស្ថារ និងកសាងអោយសហគមន៍ និងសង្គមជាតិប្រកបដោយស្ថេរភាពនិងវឌ្ឍនៈភាពជានិរន្តរ៍។

- អង្គការ និងស្ថាប័នពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ ជាពិសេសក្រុមប្រឹក្សាឃុំ គួរមានសមត្ថកិច្ច និងសមត្ថភាពគ្រប់គ្រាន់ក្នុងការពិនិត្យ តាមដាន និងវាយតម្លៃសកម្មភាពការងាររបស់ឃុំ អង្គការ ឬស្ថាប័នទាំងឡាយ ដើម្បីធានាកិច្ចអភិវឌ្ឍន៍អោយមានប្រសិទ្ធភាព និងប្រកបដោយនិរន្តរភាព។

- អាជ្ញាធរមូលដ្ឋាន គួរលើកទឹកចិត្តបន្ថែមទៀតដល់ការវិនិយោគទុន ជាសាធារណៈ និងវិស័យឯកជន ដើម្បីអោយគេពេញចិត្តក្នុងការជួយដល់មូលដ្ឋានរបស់ខ្លួន។

- ប្រព័ន្ធបណ្តាញផ្សព្វផ្សាយ និងប្រព័ន្ធទទួលព័ត៌មានទាំងឡាយ គួរជម្រុញអោយបានដល់គ្រប់ទិសទីក្នុងមូលដ្ឋាន។

# ឧបសម្ព័ន្ធ


ទម្រង់រដ្ឋ
ទម្រង់រចនាសម្ព័ន្ធដែនដី/
ទម្រង់គ្រប់គ្រងដែនដី
ទម្រង់គ្រប់គ្រង/
របបគ្រប់គ្រង
របបនយោបាយ
រដ្ឋឯកភូត (រដ្ឋទោល)
រដ្ឋសហព័ន្ធ
រដ្ឋសហសម្ព័ន្ធ
រាជាធិបតេយ្យ
សាធារណរដ្ឋ
របបឯកធិបតេយ្យ
របបពហុធិបតេយ្យ
- របបប្រជាធិបតេយ្យ
- របបសេរីនិយម
រាជានិយមផ្ដាច់ការ
រាជាធិបតេយ្យអាស្រ័យធម្មនុញ្ញ
សាធារណរដ្ឋអាស្រ័យសភា
(របបសភានិយម)
សាធារណរដ្ឋអាស្រ័យ
ប្រធានាធិបតី
សាធារណរដ្ឋពាក់កណ្ដាល
ប្រធានាធិបតី (របបចំរុះ)
អំណាចទាំងអស់ឋិតក្នុងបុគ្គល
តែម្នាក់គឺ ព្រះមហាក្សត្រ
ដូចជា ប្រ៊ុយណេ កាតា អូម៉ែន
អារ៉ាប៊ីសាអូឌីត ។
ទិ្វករាជាធិបតេយ្យ
រាជាធិបតេយ្យអាស្រ័យសភា
ហ្ស៊កដង់ គុយវ៉ែត
ម៉ូរ៉ុក្កូ ...។
អង់គ្លេស ជប៉ុន អេស្ប៉ាញ
ជាដើម ។
ដូចជា លីបង់ សិង្ហបូរី...។
ដូចជា សហរដ្ឋអាមេរិច
ម៉ាឡាវី...។
ដូចជា ប៉័ទ្បួញ បារាំង
ព័រទុយកាល់... ។




## ប្រព័ន្ធគ្រប់គ្រងរដ្ឋបាល/ការរៀបចំរដ្ឋបាល

១. មជ្ឈការ (Centralization): គឺជាការប្រមូលផ្តុំអំណាចទាំងអស់ឱ្យស្ថិតនៅលើអាជ្ញាធរកណ្តាល (ក្រសួង/ស្ថាប័ន អាជ្ញាធរ ឬគ្រឹះស្ថានសាធារណៈ) ជាអ្នកសម្រេចទាំងអស់។

២. វិសហមជ្ឈការ (Déconcentration): គឺជាការរំលែកអំណាចពីរដ្ឋបាលកណ្តាលឱ្យទៅរដ្ឋបាលនានា (ភ្នាក់ងាររដ្ឋ ឬ ខេត្ត/ក្រុង ស្រុក/ខណ្ឌ) ដើម្បីលើកកម្ពស់ប្រសិទ្ធភាពចាត់ចែងការងាររបស់រដ្ឋ។

៣. វិមជ្ឈការ (Décentralization): គឺជាការផ្ទេរអំណាចពីរដ្ឋបាលកណ្តាលឱ្យទៅរដ្ឋបាលណាមួយ (ឃុំ/សង្កាត់) ដើម្បីធ្វើការសម្រេចចាត់ចែងការងារក្នុងនាមជាប្រយោជន៍របស់មូលដ្ឋានផ្ទាល់។

**សម្គាល់:**ពាក្យទាំងបីនេះគឺជាភាសាបច្ចេកទេសប្រើសម្រាប់សម្គាល់របៀបគ្រប់គ្រងរដ្ឋបាល ហើយវាមានទស្សនទានប្លែកៗពីគ្នាទៅតាមប្រទេសនីមួយៗ តាមពេលវេលាជាដំណាក់កាល។

| | ក្របខ័ណ្ឌ | ឋានន្តរស័ក្តិ | ថ្នាក់ | |
|---|---|---|---|---|
| មន្ត្រីជាន់ខ្ពស់ | ក | ១ | ៦ ៥ ៤ ៣ ២ ១ | ឧត្តមមន្ត្រី |
| | | ២ | ១០ ៩ ៨ ៧ ៦ ៥ ៤ ៣ ២ ១ | វរៈមន្ត្រី |
| | | ៣ | ១៤ ១៣ ១២ ១១ ១០ ៩ ៨ ៧ ៦ ៥ ៤ ៣ ២ ១ | អនុមន្ត្រី |
| មន្ត្រីក្រមការ | ខ | ១ | ៦ ៥ ៤ ៣ ២ ១ | នាយក្រមការ |
| | | ២ | ១០ ៩ ៨ ៧ ៦ ៥ ៤ ៣ ២ ១ | ក្រមការដើមខ្សែ |
| | | ៣ | ១៤ ១៣ ១២ ១១ ១០ ៩ ៨ ៧ ៦ ៥ ៤ ៣ ២ ១ | ក្រមការ |
| លេខាធិការ | គ | ១ | ៦ ៥ ៤ ៣ ២ ១ | នាយលេខាធិការ |
| | | ២ | ១០ ៩ ៨ ៧ ៦ ៥ ៤ ៣ ២ ១ | លេខាធិការដើមខ្សែ |
| | | ៣ | ១៤ ១៣ ១២ ១១ ១០ ៩ ៨ ៧ ៦ ៥ ៤ ៣ ២ ១ | លេខាធិការ |
| ភ្នាក់ងាររដ្ឋបាល | ឃ | ១ | ៦ ៥ ៤ ៣ ២ ១ | នាយភ្នាក់ងារ |
| | | ២ | ១០ ៩ ៨ ៧ ៦ ៥ ៤ ៣ ២ ១ | ភ្នាកងារដើមខ្សែ |
| | | ៣ | ១៤ ១៣ ១២ ១១ ១០ ៩ ៨ ៧ ៦ ៥ ៤ ៣ ២ ១ | ភ្នាក់ងារ |

សម្គាល់៖ សម្រាប់មន្ត្រីរាជការស៊ីវិល ស្ថិតក្រោមច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល និង លក្ខន្តិកៈដោយឡែកនានា ដូចជា ក្រសួងមហាផ្ទៃ ក្រសួងសុខាភិបាល ក្រសួង អប់រំ យុវជន និងកីឡា ជាដើម។

**ការបែងចែកទឹកដីមុនឆ្នាំ២០០៨**




**ការបែងចែកទឹកដីបច្ចុប្បន្ន**



## គំនូសបំព្រួញសង្ខេប



# ឯកសារយោង


## I- ឯកសារជាភាសាខ្មែរ

1. សៀវភៅនីតិរដ្ឋបាលទូទៅ របស់លោកបណ្ឌិត សាយ បូរី ឆ្នាំ២០០២។
2. ដាវីឌអាយរ៉េស, វិមជ្ឈការ(សម្រង់អត្ថបទ), គម្រោងគាំទ្រក្រុមប្រឹក្សាឃុំសង្កាត់ (CCSP), ខែសីហា ២០០១, ភ្នំពេញ។
3. ច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់, ២០០១។
4. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, (ធ្វើវិសោធនកម្មថ្មី)។
5. ច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានីខេត្តក្រុងស្រុកខណ្ឌ, ២០០៨។
6. ច្បាប់ស្តីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ, ២០០៨។
7. ក្រសួងផែនការ, ដំណើរការរៀបចំ និងការតាមដានត្រួតពិនិត្យផែនការអភិវឌ្ឍន៍ជាតិ និងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ ក្នុងបរិបទនៃការកែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ, ឧសភា ២០០៩។
8. អុកស្វាមអង់គ្លេស-Oxfam GB, វិមជ្ឈការនិងកំណែរទម្រង់ក្រុមប្រឹក្សាឃុំ (ឱកាសជាបន្ទាន់សម្រាប់អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក, ធ្នូ២០០០។
9. ក្រសួងមហាផ្ទៃ, របាយការណ៍សិក្ខាសាលា ពីវិមជ្ឈការ និងវិសហមជ្ឈការ, កុម្ភៈ ២០០០។
10. គណៈកម្មាធិការជាតិគាំទ្រឃុំសង្កាត់(គ.ជ.ឃ/ស), ការរៀបចំគម្រោងអភិវឌ្ឍន៍ឃុំសង្កាត់វិច្ឆិកា២០០២។
11. កៅ មុយថង, វិមជ្ឈការ និងវិសហមជ្ឈការ, បោះពុម្ពលើកទី១ដោយបណ្ណាគារអង្គរ, ISBN: 978-99950-59-72-9, ២០០៧, ភ្នំពេញ។
12. អង្គការមូលនិធិអាស៊ី, វចនានុក្រមច្បាប់អង់គ្លេស-ខ្មែរ, បោះពុម្ពលើកទី១, ១៩៩៧។
13. សន គីណាល់ និងស៊ុន តាភ្វា, កម្មវិធីសិលា (វិមជ្ឈការនៅកម្ពុជា), ២០០២។

## II- ឯកសារជាភាសាបរទេស

1. Rammanie Samaratunge, DECENTRALISATION AND DEVELOPMENT: PARTNER IN THE 21ST CENTURY? January 1998.
2. Andrew N. Parker, DECENTRALIZATION, the Way Forward for Rural Development? June 1995.